

# ទំហំដែលផ្ទុកអ្នកទោសបាន ឆ្នាំ២០១២: ការវិវឌ្ឍន៍នៃរបាយការណ៍ ស្ដីពីភាពចង្អៀតណែនរបស់អ្នកទោស នៅកម្ពុជា

របាយការណ៍ លីកាដូ
ខែកក្កដា ឆ្នាំ២០១២


សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ
LICADHO
CAMBODIAN LEAGUE FOR THE PROMOTION AND DEFENSE OF HUMAN RIGHTS

# ទំហំដែលផ្ទុកអ្នកទោសបាន ឆ្នាំ២០១២: ការខចខ្សាន់នៃរបាយការណ៍ស្តីពីភាពចង្អៀតណែនរបស់អ្នកទោស នៅកម្ពុជា

របាយការណ៍ លីកាដូ

ខែកក្កដា ឆ្នាំ២០១២


សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

## សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការស្ថិតនៅជួរមុខគេក្នុងកិច្ចការពារសិទ្ធិមនុស្សនៅកម្ពុជា និងលើកស្ទួយការគោរពសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយតាមរយៈរាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័ននានា។ ការកសាងសមិទ្ធិផលរបស់ខ្លួនក្នុងអតីតកាល **លីកាដូ** បានបន្តដើរតួជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងឃ្លាំមើលរដ្ឋាភិបាលតាមរយៈកម្មវិធីសិទ្ធិមនុស្សនានាពីការិយាល័យកណ្តាលរបស់ខ្លួននៅភ្នំពេញ និងនៅតាមសាខាទូទាំង១២ ខេត្ត-រាជធានីផ្សេងទៀត។

**អង្គការលីកាដូ អនុវត្តសកម្មភាពរបស់ខ្លួនតាមរយៈកម្មវិធីធំៗពីរ:**

**កម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស:**

- **ឃ្លាំមើលការរំលោភសិទ្ធិមនុស្សដែលប្រព្រឹត្តដោយបុគ្គលរបស់រដ្ឋលើការរំលោភសិទ្ធិស្ត្រី និងការរំលោភសិទ្ធិកុមារ:** បុគ្គលិកធ្វើការស៊ើបអង្កេតលើករណីរំលោភសិទ្ធិមនុស្សដែលប្រព្រឹត្តដោយបុគ្គលរបស់រដ្ឋ ចំពោះការរំលោភបំពានលើស្ត្រី និងកុមារ ហើយជនរងគ្រោះ ត្រូវបានផ្តល់សេវាជួយជ្រោមជ្រែងតាមរយៈការធ្វើអន្តរាគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន។
- **ការប្រឹក្សាផ្នែកច្បាប់ និងកិច្ចការពារផ្នែកច្បាប់:** ជនរងគ្រោះ ត្រូវបានផ្តល់ជូននូវការប្រឹក្សាផ្នែកច្បាប់ ហើយចំពោះករណីសំខាន់ៗ ទទួលបាននូវកិច្ចការពារផ្នែកច្បាប់ដែលផ្តល់ជូនដោយក្រុមប្រឹក្សាផ្នែកច្បាប់ និងក្រុមមេធាវីការពារសិទ្ធិមនុស្ស។
- **ការឃ្លាំមើលពន្ធនាគារ:** អ្នកស្រាវជ្រាវពន្ធនាគារធ្វើការឃ្លាំមើលពន្ធនាគារចំនួន១៨ ដើម្បីធ្វើការវាយតម្លៃអំពីស្ថានភាពនៅក្នុងពន្ធនាគារ និងដើម្បីធានា ថាជនជាប់ឃុំទទួលបាននូវតំណាងផ្នែកច្បាប់។
- **ជំនួយផ្នែកវេជ្ជសាស្ត្រ:** ក្រុមគ្រូពេទ្យផ្តល់សេវាវេជ្ជសាស្ត្រដល់ជនជាប់ឃុំ និងមន្ត្រីពន្ធនាគារចំនួន១២ កន្លែង។ បន្ថែមពីលើនេះ ក៏ជួយផ្តល់សេវាវេជ្ជសាស្ត្រ និងបញ្ជូនជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្សទៅកាន់មន្ទីរពេទ្យ។

- **សេវាកម្មសង្គមកិច្ច:** ក្រុមការងារធ្វើការវាយតម្លៃពីតម្រូវការរបស់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ ហើយផ្តល់ជំនួយសម្ភារៈ និងម្ហូបអាហាររយៈពេលខ្លី។

**កម្មវិធីទំនាក់ទំនង និងការទាក់ទាញមតិគាំទ្រ:**

- **ការហ្វឹកហ្វឺនសហគមន៍ អប់រំ និងការតស៊ូមតិ:** អ្នកហ្វឹកហ្វឺន និងអ្នកតស៊ូមតិធ្វើការអប់រំដល់សាធារណជនអំពីសិទ្ធិស្ត្រី និងសិទ្ធិកុមារបង្កើតបណ្តាញការពារនៅតាមមូលដ្ឋាន និងធ្វើការតស៊ូមតិដើម្បីឲ្យមានការផ្លាស់ប្តូរសង្គម និងគោរពច្បាប់។
- **ការតស៊ូមតិជាសាធារណៈ និងតាមសហគមន៍:** ករណីរំលោភសិទ្ធិមនុស្សដែលស៊ើបអង្កេតដោយលីកាដូ ត្រូវបានចងក្រងទុកនៅក្នុងប្រព័ន្ធទិន្នន័យ ដើម្បីឲ្យមានភាពងាយស្រួលក្នុងការស្វែងរកព័ត៌មាន វិភាគ ផលិតជារបាយការណ៍ជាប្រចាំ (ការបោះពុម្ពជារបាយការណ៍ និងរបាយការណ៍សោតទស្សន៍)។

**ចំពោះព័ត៌មានបន្ថែមសូមទាក់ទង:**

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក ប្រធានអង្គការលីកាដូ

អាសយដ្ឋាន: អង្គការលីកាដូ (សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស)

ផ្ទះលេខ ១៦ ផ្លូវលេខ ៩៩ រាជធានីភ្នំពេញ កម្ពុជា

ទូរស័ព្ទ: (+៨៥៥) ២៣ ៧២៧ ១០២/២១៦ ៦០២ ទូរសារ: (+៨៥៥) ២៣ ៧២៧ ១០២/២១៧ ៦២៦

អ៊ីម៉ែល: contact@licadho-cambodia.org

គេហទំព័រ: http://www.licadho-cambodia.org

សេចក្តីអធិប្បាយនៅក្នុងរបាយការណ៍នេះ ជាការទទួលខុសត្រូវទាំងស្រុងរបស់អង្គការលីកាដូ ហើយមិនអាចយកទៅប្រើប្រាស់ក្នុងរូបភាពណាមួយដើម្បីឆ្លុះបញ្ចាំងពីទស្សនៈរបស់សហគមន៍អឺរ៉ុបឡើយ។

# មាតិកា


**សេចក្តីផ្តើម ................................................................................ ១**

អំពីរបាយការណ៍នេះ ................................................................................ ៣

**១. ភាពចង្អៀតណែន: បច្ចុប្បន្នភាពទិន្នន័យស្ទួល ...................................... ៥**

ទិន្នន័យជនជាប់ឃុំ និងការឃុំខ្លួននៅទូទាំងប្រទេស (គ្រប់ពន្ធនាគារ)............. ៥

**២. ព័ត៌មាន និងការវិវឌ្ឍន៍ក្នុងឆ្នាំ២០១១ - ២០១២ ..................................... ៨**

ការខកខានមិនអនុវត្តវិធានការផ្សេងជំនួសការដាក់ពន្ធនាគារនៅតែបន្តមាន . ៨

ការចាប់ខ្លួនក្នុងករណីគ្រឿងញៀនមានសន្ទុះកើនឡើងច្រើន.............................៩

ម្តាយ និងកូនៗកាន់តែច្រើននៅក្នុងពន្ធនាគារ: ឧប្បត្តិហេតុនៃការចាត់វិធានការណ៍លុបបំបាត់គ្រឿងញៀន....................................................................១៤

ការខកខានមិនបានទទួលសាលក្រម/សាលដីកាស្ថាពរ..................................១៦

ការផ្តន្ទាទោសជនក្រីក្រ......................................................................១៦

ការសាងសង់ពន្ធនាគារ ......................................................................១៩

ការគណនាទំហំផ្ទុក ........................................................................ ២២

**៣. ការពិនិត្យឡើងវិញនូវអនុសាសន៍នានា ............................................ ២៤**

# សេចក្តីផ្តើម

នេះគឺជារបាយការណ៍ភាគទីបី នៃរបាយការណ៍ប្រចាំឆ្នាំរបស់អង្គការលីកាដូ ស្តីពីភាពចង្អៀតណែននៅពន្ធនាគារក្នុងប្រទេសកម្ពុជា[១]។

អង្គការលីកាដូដំបូងបានរាយការណ៍អំពីកំណើនជនជាប់ឃុំឆាប់រហ័ស នៅក្នុងប្រព័ន្ធគ្រប់គ្រងពន្ធនាគារក្នុងឆ្នាំ២០១០ នៅពេលពន្ធនាគាររបស់ជាតិបានផ្ទុកជនជាប់ឃុំពេញទំហំផ្ទុករបស់ខ្លួនស្មើនឹង ១៦៧% ហើយចំនួនជនជាប់ឃុំមានការកើនឡើងប្រហែល ១៥% ជារៀងរាល់ឆ្នាំ។

នៅខែឧសភា ឆ្នាំ២០១១ អត្រាអ្នកជាប់ឃុំនៅតាមពន្ធនាគារទូទាំងប្រទេស មានចំនួនកើនឡើងរហូតដល់ ១៧៩% ចំណែកពន្ធនាគារចំនួន ១៨ ដែលអង្គការលីកាដូ[២] បានឃ្លាំមើលបានផ្ទុកជនជាប់ឃុំពេញទំហំផ្ទុករបស់ខ្លួនស្មើនឹង ១៨១%។ កំណើនជនជាប់ឃុំនៅតាមពន្ធនាគារ ដែលអង្គការលីកាដូ បានឃ្លាំមើលបានកើនឡើងជាមធ្យមប្រហែល ១៣% ក្នុងមួយឆ្នាំៗ ហើយប្រព័ន្ធគ្រប់គ្រងពន្ធនាគារកំពុងរំកិលទៅរកភាពចង្អៀតណែនបំផុតនៅលើពិភពលោកនៅឆ្នាំ២០១៩ ខាងមុខនេះ។ ជាមួយគ្នានេះ មានភស្តុតាងបង្ហាញថា អាជ្ញាធរមិនទាន់បានចាត់វិធានការជាក់ស្តែង ដើម្បីកាត់បន្ថយការពឹងពាក់ហួសហេតុទៅលើពន្ធនាគារ ដែលជាការដាក់ទណ្ឌកម្មតាមផ្លូវតុលាការមួយបែប ក្នុងដំណាក់កាលបឋម។ ឧទាហរណ៍ ពន្ធនាគារទាំងឡាយនៅតែកំពុងត្រូវបានប្រើប្រាស់ជាឃ្លាំងសម្រាប់ផ្ទុកអ្នកប្រើប្រាស់គ្រឿងញៀន ពិរុទ្ធជនដែលបានប្រព្រឹត្តបទល្មើសតូចតាច និងជនក្រីក្រដែលគ្មានលទ្ធភាពបង់ប្រាក់ពិន័យក្នុងរឿងព្រហ្មទណ្ឌ។

---

[១] សូមមើល គុកធំ-ចង្អៀតខ្លាំង: ភាពចង្អៀតណែនរបស់អ្នកទោសនៅកម្ពុជា និងក្តីស្រមៃនៃមណ្ឌលអប់រំកែប្រែទី៤ របាយការណ៍លីកាដូ ខែកក្កដា ឆ្នាំ២០១០ និង ‘ទំហំដែលផ្ទុកអ្នកទោសបានឆ្នាំ២០១១: របាយការណ៍ថ្មីៗ ស្តីពីភាពចង្អៀតណែនរបស់អ្នកទោសនៅកម្ពុជា’ របាយការណ៍លីកាដូ ខែកក្កដា ឆ្នាំ២០១១។

[២] ពន្ធនាគារទាំងនេះ មានមណ្ឌលអប់រំកែប្រែទី១ មណ្ឌលអប់រំកែប្រែទី២ មណ្ឌលអប់រំកែប្រែទី៣ មណ្ឌលអប់រំកែប្រែទី៤ ពន្ធនាគារប៉េ ហ្ស៊ី ពន្ធនាគារនៅតាខ្មៅ ពន្ធនាគារនៅព្រះសីហនុ ពន្ធនាគារនៅកំពង់ស្ពឺ ពន្ធនាគារនៅកំពត ពន្ធនាគារនៅកំពង់ឆ្នាំង ពន្ធនាគារនៅកំពង់ចាម ពន្ធនាគារនៅកំពង់ធំ ពន្ធនាគារនៅកោះកុង ពន្ធនាគារនៅពោធិ៍សាត់ ពន្ធនាគារនៅបាត់ដំបង ពន្ធនាគារនៅបន្ទាយមានជ័យ ពន្ធនាគារនៅសៀមរាប និងពន្ធនាគារនៅស្វាយរៀង។

នៅឆ្នាំ២០១២ ទីបំផុតមានការវិវឌ្ឍន៍មួយចំនួន ដែលគួរឲ្យលើកទឹកចិត្ត ថ្វីបើការវិវឌ្ឍន៍នេះមិនទាន់ឈានដល់ពេលវេលា ដែលត្រូវប្រារព្ធពិធីអបអរសាទរនៃជ័យជំនះក៏ដោយ។

ចាប់តាំងពីខែឧសភា ឆ្នាំ២០១១មក តាមស្ថិតិជនជាប់ឃុំនៅក្នុងពន្ធនាគារចំនួន ១៨ ដែលអង្គការលីកាដូបានឃ្លាំមើល មានចំនួនថេរដដែល។ គិតមកត្រឹមថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១២ ពន្ធនាគារទាំង ១៨ នេះ បានផ្ទុកជនជាប់ឃុំចំនួន ១៣.៤៦៨ នាក់ ដែលចំនួននេះ បានថយចុះ ១.៦% យ៉ាងពិតប្រាកដ បើប្រៀបធៀបនឹងខែឧសភា ឆ្នាំ២០១១។

ទោះបីយ៉ាងណាក៏ដោយ ជនជាប់ឃុំសរុបនៅទូទាំងប្រទេស មានចំនួនកើនឡើងដល់ ១៥.៣៥១ នាក់ ដែលជាចំនួនកើនតិចតួច - ចំនួនកើនស្មើនឹង ២.៣% - នៅក្នុងរយៈពេលដូចគ្នា[៣]។ អត្រាឃុំខ្លួននៅតាមពន្ធនាគារទូទាំងប្រទេសមានចំនួន ១៧០.៦% ជាការកែលំអមួយ ទៅលើតួលេខកាលពីឆ្នាំមុន ដែលមានចំនួន ១៧៩% ដោយសារមានចំនួនកន្លែងបន្ថែម។ ចំនួនកន្លែងនៅក្នុងប្រព័ន្ធពន្ធនាគាររបស់ប្រទេសកម្ពុជាយើងបានធ្វើអោយកម្ពុជាស្ថិតនៅលំដាប់លេខ ៣៥ ក្នុងចំណោមប្រទេសដែលមានភាពចង្អៀតណែន ក្នុងពិភពលោក ប៉ុន្តែលំដាប់លេខនេះមានភាពប្រសើរបន្តិច បើប្រៀបធៀបនឹងឆ្នាំកន្លងទៅដែលកម្ពុជាស្ថិតនៅលំដាប់លេខ ២៥[៤]។

ប៉ុន្តែនៅតែមានសញ្ញាគួរឲ្យព្រួយបារម្ភ។

ទោះបីមានតួលេខកើនឡើងតិចតួចសម្រាប់ឆ្នាំ២០១១ - ២០១២ ក៏ដោយ ក៏ចំនួនជនជាប់ឃុំនៅតាមពន្ធនាគារទូទាំងប្រទេស នៅតែកើនឡើងយ៉ាងច្រើនស្មើនឹង ១៥.២% ចាប់តាំងតែពីខែមីនា ឆ្នាំ ២០១០[៥]មក។ ទោះជាអត្រាឃុំខ្លួនមានការធ្លាក់ចុះក៏ដោយក៏អត្រាទាំងនេះ ទំនងជាដោយសាតែការប៉ាន់ប្រមាណស្មើរនូវភាពចង្អៀតណែន។ អាជ្ញាធរ

[៣] អគ្គនាយកដ្ឋានពន្ធនាគារមិនបានផ្តល់ព័ត៌មានបច្ចុប្បន្នភាពជាសាធារណៈទៀងទាត់ឡើយ ស្តីពីចំនួនជនជាប់ឃុំនៅតាមពន្ធនាគារនៅទូទាំងប្រទេស។ ហេតុដូច្នេះ តួលេខទាំងនេះត្រូវបានធ្វើការប្រៀបធៀបពីខែមេសា ឆ្នាំ២០១១ និងខែកុម្ភៈ ឆ្នាំ២០១២ - ជាតួលេខដែលមានស្រាប់ និងល្អបំផុតសម្រាប់បង្ហាញពីកំណើនជនជាប់ឃុំសម្រាប់រយៈពេលមួយឆ្នាំ។

[៤] ដោយយោងតាមទិន្នន័យបច្ចុប្បន្នប្រហែលអាចស្ថិតនៅលំដាប់លេខ៣៤ ក្នុងចំណោម ១៩៦នៃឋានានុក្រមដែលបានស្ទង់។ សូមពិនិត្យមើលមជ្ឈមណ្ឌលសម្រាប់ការសិក្សាពន្ធនាគារ "Entire World-Occupancy Rates" សូមចូលមើលក្នុងវេបសាយ http://prisonstudies.org/info/worldbrief/wpb_stats.php?area =all&category=wb_occupancy

[៥] អគ្គនាយកដ្ឋានពន្ធនាគារបានរាយការណ៍អំពីចំនួនជនជាប់ឃុំទូទាំងប្រទេសស្មើនឹង ១៣.៣២៥ នាក់នៅក្នុងខែមីនា ឆ្នាំ២០១០។

ពន្ធនាគារបានទទួលស្គាល់ថា តួលេខទំហំផ្ទុកមិនត្រូវបានគេគណនាជាទម្រង់តែមួយ ដូចគ្នាជាចាំបាច់នៅទូទាំងប្រព័ន្ធគ្រប់គ្រងពន្ធនាគារឡើយ។

លក្ខណៈធ្ងន់ធ្ងរបំផុតនោះ គឺបុព្វហេតុជាមូលដ្ឋាននៃវិបត្តិចង្អៀតណែននៅតែមិនទាន់ត្រូវបានគេលើកយកមកដោះស្រាយនៅឡើយ។ ការចាប់ខ្លួនក្នុងបទល្មើសគ្រឿងញៀន ស្ទើរតែកើនឡើងបួនដងក្នុងឆ្នាំ២០១១ ហើយចំនួនជនជាប់ឃុំដែលត្រូវចោទពីបទល្មើសគ្រឿងញៀន ស្ទើរតែកើនឡើងបីដងក្នុងឆ្នាំ២០១១។ នៅតែមិនទាន់មានប្រព័ន្ធដោះលែង ដោយមានលក្ខខណ្ឌ។ ជនជាប់ឃុំប្រមាណ ៣.០០០ នាក់ ជាប់ត្រាំត្រែងក្នុងពន្ធនាគារ ដោយគ្មានសាលក្រម/សាលដីកាស្ថាពរឡើយ ទុកឲ្យពួកគេប្រឈមនឹងការឃុំខ្លួនហួសការកំណត់ទោស។ ការកាត់ទោសដោយមិនឃុំខ្លួន ដូចជាទោសការងារសហគមន៍មិនទាន់ត្រូវបានអនុវត្តជាលក្ខណៈប្រព័ន្ធឡើយ។

សរុបសេចក្តីមកមានការវិវឌ្ឍន៍បន្តិចបន្តួច ចំពោះការដោះស្រាយវិបត្តិចង្អៀតណែនកាលពីឆ្នាំមុន ប៉ុន្តែនៅតែមានការងារច្រើនទៀតត្រូវបំពេញបន្ត។

## អំពីរបាយការណ៍នេះ

របាយការណ៍មុនៗរបស់អង្គការលីកាដូ ស្តីពីភាពចង្អៀតណែននៅតាមពន្ធនាគារបានផ្តល់នូវទិដ្ឋភាពរួមនៃវិបត្តិចង្អៀតណែននៅតាមពន្ធនាគារក្នុងប្រទេសកម្ពុជា លក្ខណៈស្ថិតិ និងបែបអត្ថាធិប្បាយ។ របាយការណ៍នេះ គឺជារបាយការណ៍មួយ បែបអត្ថាធិប្បាយបន្ត មានន័យថា ត្រូវយកទៅអានក្នុងបរិបទនៃរបាយការណ៍មុនៗរបស់អង្គការលីកាដូ។

ដើម្បីសម្រេចគោលដៅនេះផ្នែកទី១ នៃរបាយការណ៍នេះ មានបច្ចុប្បន្នភាពទិន្នន័យស្ថិតិស្នូលដោយផ្អែកលើតារាងនានា រាប់ទាំងរបាយការណ៍លើកទីមួយចំនួនពីររបស់អង្គការលីកាដូផង។

ផ្នែកទី២ នៃរបាយការណ៍នេះ គឺជាសេចក្តីសង្ខេប និងការធ្វើវិភាគទៅលើគន្លឹះនៃការវិវឌ្ឍន៍ទាំងឡាយ ដែលបានកើតឡើងចាប់តាំងពីមានរបាយការណ៍ចុងក្រោយរបស់អង្គការលីកាដូ ក្នុងខែកក្កដា ឆ្នាំ២០១១ ស្តីពីភាពចង្អៀតណែននៅតាមពន្ធនាគារ។ ផ្នែក

នេះមានស្ថិតិ គូសពន្យល់ពីនិន្នាការនានាផងដែរ ដែលមិនបានធ្វើវិភាគឲ្យបានពេញលេញនៅក្នុងរបាយការណ៍មុនៗ របស់អង្គការលីកាដូ។

នៅក្នុងផ្នែកចុងក្រោយនៃរបាយការណ៍នេះ យើងខ្ញុំពិនិត្យឡើងវិញនូវអនុសាសន៍សំខាន់ៗទាំងឡាយ ដែលបានធ្វើនៅក្នុងរបាយការណ៍របស់យើងក្នុងឆ្នាំ២០១០ និងឆ្នាំ២០១១ ហើយនឹងតាមដានមើលភាពរីកចំរើន ដែលបានធ្វើឡើងឆ្ពោះទៅរកការបំពេញបាននូវអនុសាសន៍ទាំងនេះ។



*អគារនាសម័យអាណានិគមស្ថិតក្នុងស្ថានភាពចាស់ទ្រុឌទ្រោមនៅក្នុងបរិវេណ នៃពន្ធនាគារខេត្តកំពត។ ពន្ធនាគារនេះ បានកសាងឡើងនៅក្នុងឆ្នាំ១៩៣៦ ដោយគិតត្រឹមខែឧសភា ឆ្នាំ២០១២ ពន្ធនាគារនេះ មានផ្ទុកអ្នកទោសចំនួន ៥៥៤ នាក់ ដែលចំនួននេះលើសពីទំហំ ដែលអាចផ្ទុកបាន ២៨០%។*

# ១. ភាពចង្អៀតណែន: បច្ចុប្បន្នភាពទិន្នន័យស្នូល

តារាង និងប្លង់ព័ត៌មាននានាខាងក្រោមនេះ ផ្ដល់នូវព័ត៌មានស្ដីពីចំនួនជនជាប់ឃុំនៅតាមពន្ធនាគារក្នុងប្រទេសកម្ពុជា។ ស្ថិតិទាំងឡាយត្រូវបានដកស្រង់ចេញពីប្រភពផ្សេងៗគ្នារាប់ទាំងការសិក្សាស្រាវជ្រាវដោយអង្គការលីកាដូ ឯកសារអគ្គនាយកដ្ឋានពន្ធនាគារ និងរបាយការណ៍នានា ចេញផ្សាយដោយប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។

ក្រាហ្វិកទី១ រៀបរាប់ពិស្ដារអំពីចំនួនជនជាប់ឃុំនៅតាមពន្ធនាគារទូទាំងប្រទេសកម្ពុជា និងអត្រាជាប់ឃុំសរុបពីខែធ្នូ ឆ្នាំ២០០៧ ដល់ខែកុម្ភៈ ឆ្នាំ២០១២ នៅចន្លោះពេលតាមកាលកំណត់ (អគ្គនាយកដ្ឋានពន្ធនាគារមិនបានផ្សព្វផ្សាយជាសាធារណៈនូវចំនួនអ្នកជាប់ឃុំជាទៀងទាត់តាមរយៈពេលកំណត់ទេ)។ បន្ទាប់ពីចំនួនជនជាប់ឃុំកើនឡើងមិនប្រែប្រួលជាច្រើនឆ្នាំ ទីបំផុតអត្រាឃុំខ្លួនបានចាប់ផ្ដើមថយចុះនៅចុងឆ្នាំ២០១១ និងដើមឆ្នាំ២០១២។ ការថយចុះកើតមានឡើងដោយសារការកើនឡើងនូវទំហំផ្ទុកនៃពន្ធនាគារ និងការថយចុះនូវអត្រាកំណើន:

## ទិន្នន័យជនជាប់ឃុំ និងការឃុំខ្លួននៅទូទាំងប្រទេស (គ្រប់ពន្ធនាគារ)




**កំណត់សម្គាល់:**

- ទិន្នន័យនេះ ដកស្រង់ពី: ខែធ្នូ ឆ្នាំ២០០៧ ខែធ្នូ ឆ្នាំ២០០៨ ខែសីហា ឆ្នាំ២០០៩ ខែធ្នូ ឆ្នាំ២០០៩ ខែមិថុនា ឆ្នាំ២០០៩ ខែមិថុនា ឆ្នាំ២០១០ ខែធ្នូ ឆ្នាំ២០១០ ខែមេសា ឆ្នាំ២០១១ ខែវិច្ឆិកា ឆ្នាំ២០១១ និងខែកុម្ភៈ ឆ្នាំ២០១២ ។
- អគ្គនាយកដ្ឋានពន្ធនាគារបានរាយការណ៍ថា ថ្មីៗទំហំផ្ទុកអ្នកទោសនៃប្រព័ន្ធពន្ធនាគារគឺ ៩០០០ នាក់ តួលេខនេះគឺបានថ្មីតាំងពីចុងឆ្នាំ២០១១ ។ នៅដើមឆ្នាំ២០១១ ទំហំផ្ទុកអ្នកទោស ត្រូវបានរាយការណ៍ថា មានចំនួនប្រហែល ៨៣៦០នាក់។ នៅឆ្នាំ២០១០ ទំហំផ្ទុកអ្នកទោសត្រូវបានរាយការណ៍ថា មានចំនួន ៨០០០នាក់។ ទិន្នន័យទំហំផ្ទុកអ្នកទោសសម្រាប់ឆ្នាំ២០០៩ គឺជាការវាយតំលៃតាមរយៈការប្រើប្រាស់គំនូស បន្ទាត់ដូចគ្នានឹងឆ្នាំ២០១០។
- ប្រភព: របាយការណ៍ផ្លូវការណ៍របស់អគ្គនាយកដ្ឋានពន្ធនាគារ បានរាយការណ៍តាមប្រព័ន្ធ ផ្សព្វផ្សាយព័ត៌មាន និងទិន្នន័យផ្សេងទៀតរបស់អគ្គនាយកដ្ឋានពន្ធនាគារ។

តារាងខាងក្រោមនេះ គូសពន្យល់អំពីចំនួនជនជាប់ឃុំតាមពន្ធនាគារចំនួន១៨ ដែល អង្គការលីកាដូបានឃ្លាំមើលសម្រាប់ឆ្នាំ២០១០ ឆ្នាំ២០១១ និងឆ្នាំ២០១២។ អត្រាឃុំខ្លួនឆ្នាំ ២០១២ សម្រាប់ពន្ធនាគារនិមួយៗត្រូវបានរៀបរាប់នៅក្នុងក្រឡោនចុងក្រោយ។ សូមកត់សម្គាល់ថា ទំហំផ្ទុកនៃពន្ធនាគារជាច្រើន បានប្រែប្រួលចាប់តាំងពីឆ្នាំ២០១០ និង ឆ្នាំ២០១១:

| ពន្ធនាគារ | ចំនួនជនជាប់ឃុំ(ខែមិថុនា ឆ្នាំ ២០១០) | ចំនួនជនជាប់ឃុំ(ខែឧសភា ឆ្នាំ២០១១) | ចំនួនជនជាប់ឃុំ (ខែឧសភា ឆ្នាំ ២០១២) | ទំហំផ្ទុក (ខែឧសភា ឆ្នាំ ២០១២) | ភាគរយសមត្ថភាពផ្ទុក (ខែឧសភា ឆ្នាំ ២០១២) |
|---|---|---|---|---|---|
| ប៉ៃលិន | ១៦៧ | ១៩២ | ១៦៨ | ២០០ | ៨៤% |
| មណ្ឌលអប់រំកែប្រែទី១ | ២,៦៩៩ | ២,៨៩៨ | ២,៨៦០ | ១,៦០០ | ១៧៨.៨% |
| មណ្ឌលអប់រំកែប្រែទី២ | ៧៧៧ | ៨១១ | ៧៣៣ | ៣០០ | ២៤៤.៣% |
| មណ្ឌលអប់រំកែប្រែទី៣ | ១,៥២៩ | ១,៥០២ | ១,៤៧៣ | ៨១០ | ១៨១.៩% |
| មណ្ឌលអប់រំកែប្រែទី៤ | ១៥៤ | ១៩៦ | ១៧៦ | ២១០ | ៨៣.៨% |
| តាខ្មៅ | ១,០៩២ | ១,០៩០ | ៩២៦ | ៣១៤ | ២៩៤.៩% |
| ព្រះសីហនុ | ៣៣២ | ៤៣៥ | ៣៦៥ | ១៥០ | ២៤៣.៣% |
| កំពង់ស្ពឺ | ៣១៣ | ៣៣៨ | ៣៥២ | ១៨០ | ១៩៥.៦% |
| កំពត | ៣៤៥ | ៤២៨ | ៤៥៤ | ១៦០ | ២៨៣.៨% |
| កំពង់ឆ្នាំង | ២៧១ | ៣៣៦ | ៤៣៦ | ១៥០ | ២៩០.៧% |
| កំពង់ចាម | ៧៩៨ | ៨៣៩ | ៨៥០ | ៦០០[៦] | ១៤១.៧% |
| កំពង់ធំ | ២០៨ | ២៧១ | ៤៣២ | ៣០០[៧] | ១៤៤% |
| កោះកុង | ២១៨ | ២៣៧ | ២៣៣ | ១៥០ | ១៥៥.៣% |
| ពោធិ៍សាត់ | ២២៩ | ២៣៣ | ២០៣ | ១២០ | ១៦៩.២% |
| បាត់ដំបង | ១,១៧៤ | ១,១៩១ | ១,២០៧ | ៦៥០ | ១៨៥.៧% |
| បន្ទាយមានជ័យ | ៨១៦ | ១,០៨៥ | ១,០៦០ | ៧០០ | ១៥១.៤% |
| សៀមរាប | ១,៣៦១ | ១,៤៨២ | ១,២៣៦ | ១,០០០ | ១២៣.៦% |
| ស្វាយរៀង | ២៦៦ | ៣១៧ | ៣០៤ | ១៦០ | ១៩០% |
| **សរុប** | **១២,៦៤៦** | **១៣,៦៨១** | **១៣,៤៦៨** | **៧,៧៥៤** | **១៧៣.៧%** |

[៦] ចំនួននេះឆ្លុះបញ្ចាំងកន្លែងបន្ថែមចំនួន ១០០ ចាប់តាំងពីខែកក្កដា ឆ្នាំ២០១១ តាមរយៈការបញ្ចប់ការសាងសង់អគារឃុំខ្លួនថ្មីមួយ។

[៧] ចំនួននេះឆ្លុះបញ្ចាំងកន្លែងបន្ថែមចំនួន ១០០ ចាប់តាំងពីខែកក្កដា ឆ្នាំ២០១១ តាមរយៈការបញ្ចប់ការសាងសង់អគារឃុំខ្លួនថ្មីមួយ។

តារាងចុងក្រោយនេះ ពិពណ៌នាអំពីអត្រាឃុំខ្លួននៅទូទាំងប្រទេសកម្ពុជា ដែលត្រូវបានកំណត់ជាចំនួនជនជាប់ឃុំក្នុងចំណោមមនុស្ស ១០០.០០០ នាក់ នៅទូទាំងប្រទេស។ ជាការលំបាកក្នុងការចង្អុលបង្ហាញឲ្យបានជាក់លាក់នូវអត្រាឃុំខ្លួន "ធម្មតា" - តួលេខទាំងឡាយ មានការប្រែប្រួលច្រើននៅជុំវិញពិភពលោក[៨] - ប៉ុន្តែអត្រាកម្ពុជាបន្តកើនឡើងជាលំដាប់ ដែលនៅតែជាបុព្វហេតុនៃកង្វល់:

### អត្រាឃុំខ្លួនទូទាំងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ២០០៦

| ឆ្នាំ | ចំនួនប្រជាពលរដ្ឋទូទាំងប្រទេស[៩] | ចំនួនជនជាប់ឃុំ | ជនជាប់ឃុំក្នុងចំណោមមនុស្ស ១០០,០០ នាក់ |
|---|---|---|---|
| ២០០៦ | ១៣,៥១៥,៨៨៤ | ១០,៣៣៨ | ៧៦.៥ |
| ២០០៧ | ១៣,៦៦៩,៨៥៧ | ១០,៩០២ | ៧៩.៨ |
| ២០០៨ | ១៣,៨២២,៦៤៤ | ១១,៦៨៨ | ៨៤.៦ |
| ២០០៩ | ១៣,៩៧៧,៩០៣ | ១៣,៣៤៥ | ៩៥.៥ |
| ២០១០ | ១៤,១៣៩,០០០ | ១៤,០៤៣ | ៩៩.៣ |
| ២០១១ | ១៤,៣៦៥,២២៤ | ១៥,៤០៤ | ១០៧.២ |
| ២០១២ | (ទិន្នន័យមិនទាន់ពេញលេញ) | | |

(ទិន្នន័យជនជាប់ឃុំនៅពន្ធនាគារ ដែលបង្ហាញនូវតួលេខទូទាំងប្រទេសនៅបំណាច់ឆ្នាំប្រតិទិននីមួយៗ)

[៨] កាសិក្សាស្រាវជ្រាវមួយដាក់អត្រាឃុំខ្លួនប្រទេសកម្ពុជា ប្រហែលនៅលំដាប់ខ្ពស់បំផុតទី២១ ក្នុងចំណោម ៣១ ប្រទេសនៅអាស៊ី។ សូមមើលមជ្ឈមណ្ឌលអន្តរជាតិសម្រាប់សិក្សាស្រាវជ្រាវកិច្ចការពន្ធនាគារ "អាស៊ី - អត្រាជនជាប់ឃុំនៅពន្ធនាគារក្នុងចំណោមមនុស្ស ១០០.០០០ នាក់នៅទូទាំងប្រទេស" មាននៅក្នុងគេហទំព័រ: http://prisonstudies.org/info/worldbrief/wpb_stats.php?area =contasia&category=wb_poprate។

[៩] ទិន្នន័យស្រង់ចេញពីគេហទំព័រ: http://data.worldbank.org/indicator/SP.POP.TOTL។ សូមកត់សម្គាល់ថា តួលេខចំនួនប្រជាពលរដ្ឋទូទាំងប្រទេសត្រូវបានកែប្រែយ៉ាងច្រើនតាមរបាយការណ៍មុនៗរបស់អង្គការលីកាដូ ដើម្បីឆ្លុះបញ្ចាំងទិន្នន័យឲ្យកាន់តែមានភាពត្រឹមត្រូវ។ ការកែសម្រួលនេះ បានកែប្រែអត្រាឃុំខ្លួនដែលបានប៉ាន់ប្រមាណកាលពីពេលមុនផងដែរ។ តួលេខសម្រាប់ឆ្នាំ២០១១ គឺជាការប៉ាន់ប្រមាណមួយផ្អែកលើតួលេខឆ្នាំ២០១០ បូកបញ្ចូលអត្រាកំណើន ១.៦%។

## ២. ព័ត៌មាន និងការវិវឌ្ឍន៍ក្នុងឆ្នាំ២០១១ - ២០១២

របាយការណ៍មុនៗរបស់អង្គការលីកាដូ បានគូសបញ្ជាក់នូវកត្តាជាច្រើន ដែលបង្កឲ្យមានភាពចង្អៀតណែននៅពន្ធនាគារ កត្តាទាំងអស់នេះនៅតែលេចឡើងជាបញ្ហា ទោះបីអត្រាកំណើនមានភាពយឺតយ៉ាវក៏ដោយ។ ការឃុំខ្លួនក្នុងពន្ធនាគារនៅតែត្រូវបានគេប្រើយ៉ាងលើសលុប ជាទណ្ឌកម្មមួយក្នុងរឿងព្រហ្មទណ្ឌ រីឯការឃុំខ្លួនបណ្ដោះអាសន្ន ដើម្បីរង់ចាំសវនាការសឹងជាការធម្មតា ជនជាប់ឃុំត្រូវបម្រើទោសពន្ធនាគារបន្ថែម ប្រសិនបើពួកគេគ្មានលទ្ធភាពបង់ប្រាក់ពិន័យក្នុងរឿងព្រហ្មទណ្ឌ ហើយជនក្រីក្រត្រូវបានគេឃុំឃាំងពីបទល្មើសតូចតាច។

ផ្នែកខាងក្រោមនេះ ផ្ដល់នូវបច្ចុប្បន្នភាពពិស្ដារ ស្ដីពីបញ្ហាមួយចំនួនក្នុងចំណោមបញ្ហាទាំងនេះ និងកំណត់វិស័យកង្វល់ថ្មីៗដែលបានកើតឡើងកាលពីឆ្នាំមុន។

### ការខកខានមិនអនុវត្តវិធានការផ្សេងជំនួសការដាក់ពន្ធនាគារនៅតែបន្តមាន

អង្គការលីកាដូ បានលើកជាអនុសាសន៍ក្នុងរបាយការណ៍ចំនួន ២ ក្នុងចំណោមរបាយការណ៍ទាំងពីរមុនថា តុលាការគួរតែប្រើវិធានការផ្សេង ជំនួសឲ្យការដាក់ពន្ធនាគារឲ្យបានច្រើនជាង ដូចជាទោសការងារសហគមន៍ ដាក់ឲ្យនៅក្រៅឃុំ និងព្យួរទោស។ ពីរឆ្នាំក្រោយមក ថ្នាក់ដឹកនាំមួយចំនួនតូចបានផ្ដល់ត្រឹមតែយោបល់ ប៉ុន្តែការអនុវត្តជាក់ស្ដែងគឺមានតិចតួចណាស់។

ការកាត់ទោសដោយមិនឃុំខ្លួន នៅតែមិនទាន់បានអនុវត្តអោយបានទូលាយនៅឡើយ ការឃុំខ្លួនបណ្ដោះអាសន្ននៅតែជាទម្លាប់ (ការដាក់ឲ្យនៅក្រៅឃុំ គឺជាករណីអញ្ញត្រកម្ម ឬ ជាករណីលើកលែង ដែលត្រូវបានគេយកមកប្រើប្រាស់តិចបំផុត) ហើយប្រព័ន្ធដោះលែងដោយមានលក្ខខណ្ឌ ដែលត្រូវបានអនុញ្ញាតតាមក្រមនីតិវិធីព្រហ្មទណ្ឌ[១០] នៅតែមិនទាន់ត្រូវបានអនុវត្តនៅឡើយ[១១] ក្នុងរយៈពេល ៥ ឆ្នាំ បន្ទាប់ពីក្រមនេះចូលជាធរមាន។

---

[១០] មាត្រា ៥១២ - ៥២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

[១១] ប្រការនេះ លេចឡើងដោយសារការខកខានរបស់ក្រសួងយុត្តិធម៌នៅតែបន្តមានក្នុងការមិនបានចេញប្រកាសអនុវត្តប្រព័ន្ធដោះលែង ដោយមានលក្ខខណ្ឌ។ មើលមាត្រា ៥២២ ("បែបបទនៃការឃ្លាំមើលតាមដាន ការត្រួតពិនិត្យ និងការបញ្ចូលទៅក្នុងសង្គមវិញនៃទណ្ឌិតនឹងត្រូវកំណត់ដោយប្រកាសរបស់ក្រសួងយុត្តិធម៌។ ប្រកាសនេះ អាចប្រគល់ឲ្យស្ថាប័នសាធារណៈ ឬឯកជននូវការបញ្ចូលទៅក្នុងសង្គមវិញនៃទណ្ឌិត")។

បន្ទាប់ពីបោះពុម្ពផ្សាយរបាយការណ៍ឆ្នាំ២០១១ របស់អង្គការលីកាដូមក រដ្ឋាភិបាលបានប្រកាសផែនការមួយចំនួន ដើម្បីអនុវត្តប្រព័ន្ធមួយ ដែលលើកទឹកចិត្តចំពោះទោសការងារសហគមន៍ សម្រាប់អនុវត្តលើបទល្មើសតូចតាច[១២]។ គម្រោងនេះ ត្រូវបានដាក់ឲ្យអនុវត្ត ដោយមានការជួយពីគម្រោងជំនួយយុត្តិធម៌ព្រហ្មទណ្ឌកម្ពុជា ឧបត្ថម្ភដោយ AusAID ដើម្បីអនុវត្តប្រព័ន្ធនេះ - យ៉ាងតិចណាស់ជាលក្ខណៈប្រព័ន្ធ - ដែលមិនអាចសម្រេចបានក្នុងរយៈពេលដ៏ខ្លី ប៉ុន្តែជិតមួយឆ្នាំ បន្ទាប់ពីការប្រកាសនេះ អង្គការលីកាដូមិនបានទទួលព័ត៌មាននូវការអនុវត្តជាក់ស្តែងណាមួយ ឆ្ពោះទៅរកកំណើននៃការប្រើប្រាស់ទោសការងារសហគមន៍ឡើយ។

ថ្មីៗនេះ ឯកឧត្តម គុយ ប៊ុនសន អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ បានមានប្រសាសន៍ទៅកាន់កាសែត Cambodia Daily នៅក្នុងខែមីនា ឆ្នាំ២០១២ ថាក្រសួងយុត្តិធម៌បានយល់ព្រមអនុវត្ត "មាត្រា ២០៥ នៃក្រមព្រហ្មទណ្ឌ" ដើម្បីសម្រួលដល់ភាពចង្អៀតណែន ដែលចង់ឃើញជនជាប់ឃុំកាត់ទោសពីបទល្មើសតូចតាច "ត្រូវបានដោះលែងនៅក្រៅឃុំ"។[១៣] ប៉ុន្តែ សំដីរបស់អគ្គនាយកទំនងជាត្រូវបានគេដកស្រង់ខុស បើមិនដូច្នោះទេប្រហែលជាលោកបានមានប្រសាសន៍ច្រឡំ ពីព្រោះមាត្រា ២០៥ នៃក្រមព្រហ្មទណ្ឌគឺជាបទបញ្ញត្តមួយ ដែលបន្ថែមទម្ងន់ទណ្ឌកម្ម សម្រាប់បទឃាតកម្មដោយមានទារុណកម្ម ឬអំពើរំលោភសេពសន្ថវៈ។ លោកប្រហែលជាចង់មានប្រសាសន៍សំដៅទៅលើមាត្រា ១០៤ និងមាត្រា ១០៥ ដែលទាក់ទងនឹងទោសព្យួរ។ ទោះបីយ៉ាងណាក៏ដោយ ទោសទាំងនេះត្រូវតែកំណត់ដោយតុលាការផ្អែកលើករណីនីមួយៗ។

## ការចាប់ខ្លួនក្នុងករណីគ្រឿងញៀនមានសន្ទុះកើនឡើងច្រើន

ចាប់តាំងពីខែមករា ឆ្នាំ២០១១ ពន្ធនាគារកម្ពុជាត្រូវបានគេមើលឃើញថា មានការកើនឡើងយ៉ាងខ្លាំងនូវចំនួនជនជាប់ឃុំ ដែលត្រូវបានចោទប្រកាន់ទាក់ទងនឹងគ្រឿងញៀន។ បញ្ហានេះ ត្រូវបានធ្វើវិភាគនៅក្នុងរបាយការណ៍ឆ្នាំ២០១១ របស់អង្គការលីកាដូ ប៉ុន្តែទិន្នន័យថ្មីសម្រាប់ឆ្នាំ២០១២ គ្រាន់តែគូសបញ្ជាក់ថា សន្ទុះនៃការកើនឡើងមានទំហំ

[១២] Mary Kozlovski និងមាស សុខជា "ផែនការទោសការងារសហគមន៍" កាសែត Phnom Penh Post ចេញផ្សាយថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១១។

[១៣] KuchNaren និងKate Bartlett " ពន្ធនាគារកម្ពុជា ដែលមានសមត្ថភាពផ្ទុកស្មើនឹង ១៧១% ក្នុងឆ្នាំ២០១១" កាសែត Cambodia Daily ចេញផ្សាយថ្ងៃទី ២២ ខែមីនា ឆ្នាំ២០១២។

ប៉ុណ្ណា។ ច្បាស់ណាស់ដែលថាការចាប់ខ្លួនក្នុងករណីគ្រឿងញៀន នាំឲ្យចំនួនជនជាប់ឃុំមួយផ្នែកធំនៅតាមពន្ធនាគារមានការកើនឡើងយ៉ាងឆាប់រហ័ស។

តារាងខាងក្រោមធ្វើការប្រៀបធៀបចំនួនជនជាប់ឃុំ - ទាំងពិរុទ្ធជន និងទណ្ឌិត - ដែលត្រូវបានឃុំខ្លួនតាមការចោទប្រកាន់ទាក់ទងនឹងគ្រឿងញៀន នៅក្នុងខែមករា ឆ្នាំ ២០១១ និងខែកុម្ភៈ ឆ្នាំ២០១២។ តារាងនេះ ពិពណ៌នាអំពីទិន្នន័យក្នុងពន្ធនាគារចំនួន ១៣ ដោយសារតែអគ្គនាយកដ្ឋានពន្ធនាគារមិនបានផ្តល់ជូនអង្គការលីកាដូ នូវស្ថិតិពេញលេញស្របគ្នាស្តីពីបទល្មើសដែលត្រូវបានចោទប្រកាន់ទៅលើជនជាប់ឃុំ។[១៤]

**ការប្រៀបធៀបស្ថិតិបទល្មើសគ្រឿងញៀនក្នុងពន្ធនាគារចំនួន១៣**
**(ខែមករា ឆ្នាំ២០១១ ប្រៀបធៀបនឹងខែកុម្ភៈ ឆ្នាំ២០១២)**

| ពន្ធនាគារ | ខែមករា ឆ្នាំ២០១១ | | | ខែកុម្ភៈ ឆ្នាំ២០១២ | | | កំណើន |
|---|---|---|---|---|---|---|---|
| | ជួញដូរ | ប្រើប្រាស់ | សរុប | ជួញដូរ | ប្រើប្រាស់ | សរុប | |
| ព្រះសីហនុ | ០ | ០ | ០ | ៨០ | ០ | ៨០ | ∞ |
| កំពង់ស្ពឺ | ៩ | ០ | ៩ | ២១ | ១០ | ៣១ | ២៤៤% |
| កំពត | ២០ | ០ | ២០ | ២៤ | ០ | ២៤ | ២០% |
| កំពង់ចាម | ៤៦ | ៣២ | ៧៨ | ៩៧ | ៧៨ | ១៧៥ | ១២៤% |
| កំពង់ឆ្នាំង | ៥ | ០ | ៥ | ១៤ | ០ | ១៤ | ១៨០% |
| កំពង់ធំ | ៨ | ០ | ៨ | ៣៣ | ២ | ៣៥ | ៣៣៨% |
| ពោធិ៍សាត់ | ២ | ០ | ២ | ៩ | ០ | ៩ | ៣៥០% |
| បាត់ដំបង | ៨៥ | ០ | ៨៥ | ៧៩ | ១១២ | ១៩១ | ១២៥% |
| បន្ទាយមានជ័យ | ១១៨ | ១៤ | ១៣២ | ៣៣២ | ១៣១ | ៤៦៣ | ២៥១% |
| សៀមរាប | ៧១ | ៧៩ | ១៥០ | ៩២ | ១១៥ | ២០៧ | ៣៨% |
| ស្វាយរៀង | ៦ | ០ | ៦ | ៩ | ០ | ៩ | ៥០% |
| កោះកុង | ៣ | ០ | ៣ | ២១ | ០ | ២១ | ៦០០% |
| មណ្ឌលអប់រំកែប្រែទី៣ | ៦៨ | ០ | ៦៨ | ៦៨ | ០ | ៦៨ | -- |
| **សរុប** | **៤៤១** | **១២៥** | **៥៦៦** | **៨៧៩(៩៩%↑)** | **៤៤៨(២៥៨%↑)** | **១,៣២៧** | **១៣៤%** |

[១៤] ទិន្នន័យទៀងទាត់ដែលអគ្គនាយកដ្ឋានពន្ធនាគារផ្តល់ទៅឲ្យអង្គការលីកាដូ កំណត់យ៉ាងច្បាស់លាស់អំពី "ការជួញដូរគ្រឿងញៀន" និង "ការប្រើប្រាស់ថ្នាំញៀន" ដែលជាប្រភេទទាក់ទងនឹងថ្នាំញៀនពីរបែប។ ទិន្នន័យបទល្មើសព្រហ្មទណ្ឌមិនបានយោងទៅរកបទបញ្ញត្តិជាក់លាក់ក្នុងច្បាប់ព្រហ្មទណ្ឌឡើយ។ តួលេខសម្រាប់ប្រភេទបទល្មើសព្រហ្មទណ្ឌទាំងពីរបែបក្នុងតារាងនេះ គឺដាក់បញ្ចូលពិរុទ្ធជនជាមួយទណ្ឌិត។ សូមកត់សម្គាល់ផងដែរថា ភាពខុសគ្នារវាង "ការប្រើប្រាស់" និង"ការជួញដូរ" តែងតែមិនត្រូវបានគាំទ្រដោយអង្គហេតុនៃករណីឡើយ។ តាមការសិក្សាស្រាវជ្រាវពីអង្គការលីកាដូ បង្ហាញឲ្យឃើញថា ករណី "ប្រើប្រាស់" ជាក់ស្តែងជាញឹកញាប់បានក្លាយទៅជាកម្មវត្ថុនៃការចោទប្រកាន់ពីបទជួញដូរ ផ្អែកលើភស្តុតាងមិនគ្រប់គ្រាន់ ឬគ្មានភស្តុតាងសោះ។ ការឧទាហរណ៍មួយ គឺមានករណីប្រឆាំងនឹងសួស ចន្ថា ជាប្រធានសហជីពដែលត្រូវបានកាត់ទោសពីបទជួញដូរគ្រឿងញៀន (ក្រោយមកបញ្ចុះទោសនៅត្រឹមបទចែកចាយទៅវិញ) នៅពេលដែលគាត់កាន់ថ្នាំញៀនចំនួនដ៏តិចតួច (សូមមើល សួស ចន្ថា ត្រូវបានដោះលែង ប៉ុន្តែដំកល់ការចោទប្រកាន់ខាងព្រហ្មទណ្ឌ ដែលមិនត្រឹមត្រូវ" យុទ្ធនាការសំលៀកបំពាក់ស្អាតស្អំនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ មានក្នុងគេហទំព័រ: http://www. cleanclothes .org/news/sous-chantha-released-but-contrived-criminal-charges-upheld ហើយ "អ្នកគាំទ្រប្រមូលផ្តុំគ្នានៅខាងក្រៅពន្ធនាគារជាតិកម្ពុជា ដើម្បីស្វែងរកការដោះលែងប្រធានសហជីពដែលត្រូវជាប់ពន្ធនាគារ" សេចក្តីប្រកាសព័ត៌មានពីអង្គការលីកាដូនៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ មានក្នុងគេហទំព័រ: http://www.licadho-cambodia.org/articles/20110121/130/index.html)។

ចំនួនជនជាប់ឃុំ ដែលត្រូវបានចាប់ខ្លួនត្រូវចោទប្រកាន់ទាក់ទងនឹងគ្រឿងញៀន បានកើនឡើងលើសទ្វេដងក្នុងរយៈពេល ១៣ ខែ។

ដោយក្រលេកមើលពេលវេលាពីអតីតកាលឡើងវិញ ការកើនឡើងនេះរិតតែមានលក្ខណៈធ្ងន់ធ្ងរថែមទៀត នៅក្នុងខែមករាឆ្នាំ២០០៨ ពន្ធនាគារចំនួន ១៣ ខាងលើមានចំនួនជនជាប់ឃុំសរុប ៣៦៩ នាក់ ដែលត្រូវចោទប្រកាន់ទាក់ទងនឹងគ្រឿងញៀន។ នៅក្នុងខែមករា ឆ្នាំ២០០៩ នៅតែមានចំនួនជនជាប់ឃុំ ៣៨៥ នាក់ ថែមទៀត។ នៅខែកុម្ភៈ ឆ្នាំ២០១២ មានចំនួនជនជាប់ឃុំកើនឡើងជិត ៤ ដង[១៥]។



*ជនជាប់ចោទពីបទល្មើសគ្រឿងញៀននៅក្នុងមជ្ឈមណ្ឌលស្តារនីតិសម្បទាក្នុងខេត្តបន្ទាយមានជ័យ។ ជនជាប់ឃុំទាំងនេះ ជាទូទៅមិនត្រូវបានអនុញ្ញាតអោយចាកចេញឡើយ។*

ជាការលំបាកក្នុងការទទួលបានទិន្នន័យត្រឹមត្រូវទូទាំងប្រទេស ប៉ុន្តែអគ្គនាយកដ្ឋានពន្ធនាគារពិតជាបានផ្សព្វផ្សាយទិន្នន័យមានកំណត់ក្នុងខែកុម្ភៈ ឆ្នាំ២០១២ ដោយធ្វើការប្រៀបធៀបព័ត៌មានពិស្តារចំនួនពីរស្តីពីចំនួនជនជាប់ឃុំ - ព័ត៌មានទីមួយនៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១០ និងព័ត៌មានមួយទៀតនៅថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០១១។

ទិន្នន័យនេះ មានភាពជាក់លាក់ជាងតួលេខ ដែលបានផ្តល់មកឲ្យអង្គការលីកាដូ ដោយបំបែកបទល្មើសគ្រឿងញៀនឲ្យទៅជាប្រភេទបទល្មើសចំនួន ៥ ដោយឡែកៗពីគ្នា។ លទ្ធផលដែលបានមកកាន់តែធ្វើអោយបារម្ភៈ ជនជាប់ឃុំដែលត្រូវចោទប្រកាន់ទាក់ទងនឹងគ្រឿងញៀនមានចំនួនកើនឡើងជិតបីដងក្នុងមួយឆ្នាំះ

[១៥] សូម្បីនៅខែមករា ឆ្នាំ២០១០ ពន្ធនាគារចំនួន ១៣ បានរាយការណ៍អំពីចំនួនជនជាប់ឃុំតែ ៥១៩ នាក់ប៉ុណ្ណោះ ដែលត្រូវចោទប្រកាន់ទាក់ទងនឹងគ្រឿងញៀន។

## ការប្រៀបធៀបស្ថិតិបទល្មើសគ្រឿងញៀនទូទាំងប្រទេស
## (ខែវិច្ឆិកា ឆ្នាំ២០១០ ប្រៀបធៀបនឹងខែវិច្ឆិកា ឆ្នាំ២០១១)[១៦]

| បទល្មើស | ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ ២០១០ | ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ ២០១១ | ភាពខុសគ្នា |
|---|---|---|---|
| ចែកចាយគ្រឿងញៀន | ២៩២ | ៥៤១ | កំណើន ៨៥% |
| ជួញដូរគ្រឿងញៀន | ៦៨៨ | ១,៩៧៤ | កំណើន ១៨៧% |
| ប្រើប្រាស់គ្រឿងញៀន | ៥៥ | ២២៧ | កំណើន ៣១៣% |
| ផលិតគ្រឿងញៀន | ២ | ២ | -- |
| ជម្រុញនិងជួយសម្រួលក្នុងការផលិត ឬចែកចាយ | ៩ | ៣ | (ថយចុះ ២០០%) |
| **សរុប** | **១,០៤៦** | **២,៧៤៧** | **កំណើន ១៦៣%** |

តាមពិតមិនគួរឲ្យភ្ញាក់ផ្អើលទេដែលថា ការចាប់ខ្លួនទាក់ទងនឹងគ្រឿងញៀនកំពុងតែជម្រុញចំនួនជនជាប់ឃុំនៅពន្ធនាគារឲ្យកាន់តែកើនឡើងយ៉ាងឆាប់រហ័ស។ កាលពីឆ្នាំកន្លងទៅ គេបានឃើញការបង្ក្រាបយ៉ាងធំមួយទៅលើបទល្មើសគ្រឿងញៀន ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានជារឿយៗ បានពិពណ៌នាអំពីរឿងរ៉ាវរបស់អាជ្ញាធរ ដែលអះអាងពីចំនួនចាប់ខ្លួន។[១៧]

យោងតាមកាសែត *Phnom Penh Post*[១៨] ពួកគេទាំងអស់បានប្រាប់ឲ្យដឹងថាចំនួនការកាត់ឲ្យជាប់ទោស ទាក់ទងនឹងថ្នាំញៀនបានកើនឡើងជិត ៤ ដងនៅអំឡុងឆ្នាំ២០១១ គឺកើនពី ២៤៨ ក្នុងឆ្នាំ២០១០ រហូតដល់ ៩៥១ ក្នុងឆ្នាំ២០១១។ ការចាប់ខ្លួនមានសន្ទុះពី ៨៦៤ រហូតឡើងដល់ ១,៣០០។

---

[១៦] សូមមើលអគ្គនាយកដ្ឋានពន្ធនាគារ "របាយការណ៍ស្ដីពីសមិទ្ធិផលការងារក្នុងឆ្នាំ២០១១ និងគោលដៅសម្រាប់ឆ្នាំ២០១២" ចេញផ្សាយ នៅខែកុម្ភៈ ឆ្នាំ២០១២ (បកប្រែក្រៅផ្លូវការជាភាសាអង់គ្លេស)។

[១៧] សូមមើលឧទាហរណ៍ បុត្ររាស្មីគង្គា "ករណីគ្រឿងញៀនបង្កើនល្បឿន" កាសែត Phnom Penh Post ចេញផ្សាយថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១១ (កត់សម្គាល់ឃើញថានៅក្នុងខែកញ្ញា ឆ្នាំ២០១១ ការចាប់ខ្លួនទាក់ទងនឹងគ្រឿងញៀនបានកើនឡើងបីដង បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នានៅឆ្នាំ២០១០។ ឧត្តមសេនីយ៍ទោ ខៀវ សាម៉ន អគ្គលេខាធិការស្ដីទីនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនក្រសួងមហាផ្ទៃបានមានប្រសាសន៍ថា ការចាប់ខ្លួនបានបង្ហាញពី "ការប្ដេជ្ញាចិត្តយ៉ាងខ្លាំងដើម្បី [បង្ក្រាបគ្រឿងញៀន]" និងប្រយុទ្ធប្រឆាំងនឹង "ការជួញដូរ និងប្រើប្រាស់ថ្នាំញៀន")។

[១៨] បុត្ររាស្មីគង្គា និងKristin Lynch "ការកាត់ទោសក្នុងរឿងគ្រឿងញៀនមានសន្ទុះកើនឡើងយ៉ាងឆាប់រហ័ស" កាសែត Phnom Penh Post ចេញផ្សាយថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២។

ថ្វីបើអ្នកជំនាញភាគច្រើនយល់ព្រមថាការជួញដូរគ្រឿងញៀន គឺជាបញ្ហាដែលកំពុងតែរីកធំឡើងនៅកម្ពុជាក៏ដោយ ក៏មិនមានការបញ្ជាក់ឲ្យបានច្បាស់ថា ការបង្ក្រាបថ្នាំញៀនបានដោះស្រាយបញ្ហានេះយ៉ាងពិតប្រាកដនៅឡើយ។ សម្រាប់ជាឧទាហរណ៍ ទោះជាការចាប់ខ្លួនមានការកើនឡើងក៏ដោយ ក៏ចំនួនថ្នាំញៀនដែលរឹបអូសបានក្នុងពេលចុះបង្ក្រាបបានកើនឡើងតិចតួចពី ៣១ តោននៅឆ្នាំ២០១០ ទៅ ៣៤ តោននៅឆ្នាំ២០១១។[១៩] ប្រការនេះបង្ហាញថា អាជ្ញាធរអាចផ្តោតមុខសញ្ញាទៅលើអ្នកឆ្លៀតឱកាសជួញដូរគ្រឿងញៀនតូចតាច - និងអ្នកប្រើប្រាស់ថ្នាំញៀនសាមញ្ញ - ដើម្បីបង្កើនចំនួននៃការចាប់ខ្លួន។

ជាពិសេសការចាប់ខ្លួនអ្នកប្រើប្រាស់សារធាតុញៀន គឺជាយុទ្ធសាស្ត្រប្រព័ន្ធយុត្តិធម៌ ព្រហ្មទណ្ឌមួយដែលមានបញ្ហា។ អ្នកជំនាញយល់ព្រមយ៉ាងទូលំទូលាយថា អ្នក



*ម្តាយ និងកូនដែលជាប់ឃុំក្នុងពន្ធនាគារខេត្តប៉ៃលិន។ អ្នកទោសជាបុរសចំណាយពេលភាគច្រើននៅក្នុងរនាំងដែក ដែលអាចមើលឃើញក្នុងរូបភាព*

[១៩] ដកស្រង់ចេញពីប្រភពឯកសារដូចគ្នា។

ប្រើថ្នាំញៀនមិនគួរត្រូវបានឃុំខ្លួនឡើយ[២០]។ ការឃុំខ្លួនអ្នកប្រើថ្នាំញៀនក្នុងពន្ធនាគារជំនួសការព្យាបាល គឺជាវិធីដោះស្រាយមួយមិនប្រក្រតី និងគ្មានប្រសិទ្ធភាព ហើយថែមទាំងចំណាយថវិកាច្រើន។ ប្រសិនបើ រដ្ឋាភិបាលលោកយកចិត្តទុកដាក់យ៉ាងម៉ឺងម៉ាត់ចំពោះការព្យាបាលអ្នកប្រើគ្រឿងញៀន ដែលជាវិធានការជំនួសការឃុំខ្លួនក្នុងពន្ធនាគារ រដ្ឋាភិបាលលោកគួរតែពិនិត្យមើលកម្មវិធីព្យាបាលនៅតាមសហគមន៍ ដែលអ្នកចូលរួមអាចទៅផ្ទះដោយសេរីនៅពេលយប់។

## ម្តាយ និងកូនៗកាន់តែច្រើននៅក្នុងពន្ធនាគារៈ ឧប្បត្តិហេតុនៃការចាត់ចែងការណ៍លុបបំបាត់គ្រឿងញៀន

ផលប៉ះពាល់នៃការកើនឡើងនូវការចាប់ខ្លួនទាក់ទងនឹងថ្នាំញៀន គឺជាការកើនឡើងស្របគ្នានូវចំនួនកុមាររស់នៅជាមួយម្តាយរបស់ពួកគេនៅតាមពន្ធនាគារ។

គិតមកត្រឹមខែមីនា ឆ្នាំ២០១១ មានកុមារចំនួន ៣៦ នាក់ប៉ុណ្ណោះកំពុងស្នាក់នៅជាមួយម្តាយរបស់ពួកគេនៅតាមពន្ធនាគារចំនួន ១៨ ដែលអង្គការលីកាដូបានឃ្លាំមើល។ ប៉ុន្តែនៅខែឧសភា ឆ្នាំ២០១២ តួលេខនេះ បានកើនឡើងលើសពីពីរដង ដែលមានក្មេងស្មើនឹង៧៣នាក់។ តួលេខនេះ មិនបានរាប់បញ្ចូលក្មេងប្រមាណ ២០នាក់ទៀតដែលកំពុងស្នាក់នៅក្នុងពន្ធនាគារខេត្តប៉ៃលិនឡើយ។ ចំនួនក្មេងកំពុងរស់នៅក្នុងពន្ធនាគារបានកើនឡើងច្រើនបំផុតនៅតាមតំបន់ជាយដែនជាប់ប្រទេសថៃ - ខេត្តបន្ទាយមានជ័យ ប៉ៃលិន និងខេត្តបាត់ដំបង - ដែលជាគោលដៅរត់ពន្ធថ្នាំញៀនកម្រិតខ្ពស់ជាងគេ។

ជាតួយ៉ាងក្មេងៗត្រូវទៅស្នាក់នៅក្នុងពន្ធនាគារជាមួយម្តាយ - ឬជាមួយឪពុករបស់ពួកគេ នៅពេលគ្មានក្រុមគ្រួសារផ្សេងទៀតនៅថែទាំ និងចិញ្ចឹមបីបាច់ពួកគេនៅខាងក្រៅ។

នៅខេត្តប៉ៃលិនអ្នកស្រាវជ្រាវអង្គការលីកាដូ បានធ្វើកិច្ចសម្ភាសន៍ជាមួយគ្រួសារមួយដែលមានសមាជិកទាំងអស់ ៨នាក់ ក្នុងនោះលីកាដូបានធ្វើកិច្ចសម្ភាសន៍ជាមួយជីដូន

[២០] តាមពិត "សង្គ្រាមគ្រឿងញៀន" ទាំងមូលដោយសង្កត់ធ្ងន់លើការកំណត់ការប្រើប្រាស់សារធាតុញៀនជាបទល្មើសឧក្រិដ្ឋ បានស្ថិតក្រោមការពិនិត្យតាមដានយ៉ាងហ្មត់ចត់។ ក្រុមប្រឹក្សាពិភពលោកដែលមានអតីតប្រមុខរដ្ឋនានា និងមន្ត្រីអង្គការសហប្រជាជាតិបានហៅសង្គ្រាមនេះ ថាជា "ការបរាជ័យ" ទាំងស្រុងមួយនៅខែមិថុនា ឆ្នាំ២០១១។ យោងតាមការប៉ាន់ប្រមាណពីអង្គការសហប្រជាជាតិ "មានអ្នកប្រើសារធាតុញៀនប្រមាណ ២៥០ លាននាក់ក្នុងពិភពលោក។ 'ជាធម្មតាយើងមិនអាចចាត់អ្នកទាំងនោះ ថាជាឧក្រិដ្ឋជនបានឡើយ "TuThanh Ha, "War on drug 'a failure," សេចក្តីប្រកាសជាអន្តរជាតិ The Globe and Mail ខែមិថុនា ឆ្នាំ២០១១ ដែលអាចចូលមើលតាមរយៈគេហទំព័រ: http://globalcommissionondrugs.org/Report ។

ជីតា ម្តាយឪពុក និងកូន។ អ្នកទាំងនោះ ត្រូវបានឃុំខ្លួនក្រោមបទចោទប្រកាន់ទាក់ទងនឹងថ្នាំញៀន ប៉ុន្តែនៅពេលធ្វើកិច្ចសម្ភាសន៍ទើបដឹងយ៉ាងច្បាស់ថា អាជ្ញាធរបានរកឃើញបុគ្គលតែម្នាក់គត់ថាជាភាគីមានកំហុស។ គ្មានហេតុផលណាជាក់ស្តែងដែលត្រូវបានលើកមកសំអាង ដើម្បីចាប់ខ្លួនសមាជិកទាំងអស់របស់គ្រួសារនេះទាល់តែសោះ ក្រៅតែពីបំភិតបំភ័យជនសង្ស័យ ហើយនិងបង្កើនតួលេខចាប់ខ្លួន។

ច្បាស់ណាស់ដែល ថាការចាប់ខ្លួនទាក់ទងនឹងគ្រឿងញៀន បណ្តាលឲ្យមានការកើនឡើងនូវចំនួនកុមារដែលត្រូវទៅរស់នៅក្នុងពន្ធនាគារជាមួយម្តាយរបស់ពួកគេ។ នៅតាមពន្ធនាគារទាំង ១៨ ដែលអង្គការលីកាដូ បានឃ្លាំមើល មានស្ត្រីជាប់ឃុំចំនួន ៧៨ នាក់មានផ្ទៃពោះ និងមានកូនមួយ ឬច្រើនស្នាក់នៅជាមួយស្ត្រីទាំងនោះ។ ស្ត្រី ៥៥ នាក់ក្នុងចំណោមស្ត្រីទាំងអស់ត្រូវបានឃុំខ្លួនក្នុងពន្ធនាគារពីបទល្មើសគ្រឿងញៀនៈ

**ម្តាយជាប់ពន្ធនាគារ[២១] ពីបទល្មើសគ្រឿងញៀន**
**(ខែមីនា ឆ្នាំ២០១១ ប្រៀបធៀបនឹងខែឧសភា ឆ្នាំ២០១២)**

| ពន្ធនាគារ | ម្តាយជាប់ឃុំក្នុងពន្ធនាគារ (ខែមីនា ឆ្នាំ២០១១) | | ម្តាយជាប់ឃុំក្នុងពន្ធនាគារ (ខែឧសភា ឆ្នាំ២០១២) | |
|---|---|---|---|---|
| | ចំនួនសរុប | ចំនួនបទល្មើសគ្រឿងញៀន | ចំនួនសរុប | ចំនួនបទល្មើសគ្រឿងញៀន |
| មណ្ឌលអប់រំកែប្រែទី២ | ១៦ | ៩ | ១៥ | ៩ |
| តាខ្មៅ | ២ | ១ | ១ | ០ |
| កោះកុង | ១ | ១ | ១ | ១ |
| ពោធិ៍សាត់ | ៣ | ០ | ១ | ០ |
| បាត់ដំបង | ៥ | ២ | ១៦ | ១១ |
| បន្ទាយមានជ័យ | ៨ | ២ | ២៥ | ២១ |
| សៀមរាប | ៤ | ២ | ១១ | ៧ |
| ព្រះសីហនុ | ០ | ០ | ៧ | ៦ |
| កំពត | ១ | ០ | ១ | ០ |
| កំពង់ឆ្នាំង | ២ | ០ | ០ | ០ |
| កំពង់ចាម | ២ | ០ | ០ | ០ |
| **សរុប** | **៤៤** | **១៧(៣៩%)** | **៧៨** | **៥៥(៧១%)** |

[២១] ត្រូវបានកំណត់ថាជាស្ត្រីមានផ្ទៃពោះ និងស្ត្រីកំពុងរស់នៅក្នុងពន្ធនាគារជាមួយកូនរបស់ពួកគេ។ យោងតាមច្បាប់កូនក្មេងត្រូវបានអនុញ្ញាតឲ្យស្នាក់នៅជាមួយម្តាយរបស់ខ្លួនក្នុងពន្ធនាគាររហូតដល់មានអាយុ ៣ ឆ្នាំ (សូមមើលច្បាប់ពន្ធនាគារត្រង់មាត្រា ៤១) តាមការអនុវត្តជាក់ស្តែងកូនក្មេងជាញឹកញាប់ត្រូវបានអនុញ្ញាតឲ្យស្នាក់នៅជាមួយម្តាយក្នុងពន្ធនាគាររហូតដល់ពួកគេមានអាយុ ៦ ឆ្នាំ។

## ការខកខានមិនបានទទួលសាលក្រម/សាលដីកាស្ថាពរ

នៅក្នុងខែកុម្ភៈ ឆ្នាំ២០១២ អគ្គនាយកដ្ឋានពន្ធនាគារបានប្រកាសក្នុងរបាយការណ៍ប្រចាំឆ្នាំ ថាជនជាប់ឃុំចំនួន៣.៥៩៧ នាក់មិនទាន់បានទទួលសាលក្រម/សាលដីកាស្ថាពររបស់ពួកគេពីតុលាការឡើយ។[២២] ការដែលមិនមានសាលក្រម/សាលដីកាស្ថាពរគឺបណ្តាលអោយមានបញ្ហាពីរយ៉ាងតិច។ បញ្ហាទីមួយ គឺអាចពន្យារដល់ការដោះលែងជនជាប់ឃុំ និងបញ្ហាទីពីរ គឺធ្វើអោយអាក់ខានដល់ជនជាប់ឃុំក្នុងការដាក់ពាក្យសុំបន្ធូរបន្ថយ ឬសុំលើកលែងទោស។

ជារឿយៗជនជាប់ឃុំរាយការណ៍ប្រាប់អង្គការលីកាដូ ថាពួកគេតម្រូវឲ្យបង់ប្រាក់ដើម្បីទទួលបានច្បាប់ចម្លងនៃសាលក្រម/សាលដីកាស្ថាពរទាំងនេះ។ ជនជាប់ឃុំដែលគ្មានលទ្ធភាពបង់ប្រាក់ជារឿយៗត្រូវបានឃុំខ្លួនលើសកម្រិតទោសដែលបានកំណត់។

នៅក្នុងខែមីនា ឆ្នាំ២០១២ កាសែត The Cambodia Daily បានរាយការណ៍ថា ឯកឧត្តម អង្គ វង្សវឌ្ឍានា រដ្ឋមន្ត្រីក្រសួងយុត្តិធមិបានចេញបញ្ជាដល់មន្ត្រីតុលាការដើម្បីពន្លឿនចំណាត់ការនៃសាលក្រម/សាលដីការស្ថាពរទាំងនេះ [២៣] ។ អ្នកស្រាវជ្រាវអង្គការលីកាដូកំពុងតែឃ្លាំមើលការអនុវត្តបទបញ្ជានេះ ប៉ុន្តែយើងនៅមិនទាន់អាចវិនិច្ឆ័យអំពីលទ្ធផលនៅក្នុងរយៈពេលដ៏ខ្លីនេះបានឡើយ ។

## ការផ្តន្ទាទោសជនក្រីក្រ

របាយការណ៍ចុងក្រោយរបស់អង្គការលីកាដូ បានលើកឧទាហរណ៍ជាច្រើនទាក់ទងនឹងបុគ្គល ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពីបទល្មើសតូចតាច ដូចជាលួចស្បៀងអាហារបន្តិចបន្តួច អាហាររបស់សត្វចិញ្ចឹម ឬជ័រកៅស៊ូជាដើម។ ជនជាប់ចោទមួយរូបទទួលទោសពន្ធនាគារមួយឆ្នាំពីបទលួចមាន់មួយក្បាល។

ជនត្រូវចោទក្នុងករណីបែបនេះ ភាគច្រើនជាជនក្រីក្រ ហើយពន្ធនាគារជានិច្ចកាលមិនមែនជាកន្លែងយ៉ាងសាកសមក្នុងការដាក់ទោសឡើយ។ ប៉ុន្តែទំនងជាគ្មានលទ្ធភាព -

---

[២២] សូមមើលអគ្គនាយកដ្ឋានពន្ធនាគារ "របាយការណ៍ស្តីពីសមិទ្ធិផលការងារនៅឆ្នាំ២០១១ និងគោលដៅសម្រាប់ឆ្នាំ២០១២" បោះពុម្ពផ្សាយនៅខែកុម្ភៈ ឆ្នាំ២០១២ (បកប្រែក្រៅផ្លូវការជាភាសាអង់គ្លេស)។

[២៣] KuchNaren and Kate Bartlett, "ជនជាប់ឃុំលើសពី ៣.០០០ នាក់កំពុងរង់ចាំសាលក្រមពីតុលាការ" កាសែត The Cambodia Daily ចេញផ្សាយថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១២។

ឬក៏គ្មានឆន្ទៈ - ដើម្បីបង្វែរជនត្រូវចោទពីបទល្មើសតូចតាចឲ្យផុតពីការដាក់ទោសពន្ធនាគារ។

អង្គការលីកាដូ នៅតែបន្តចងក្រងជាឯកសារនូវករណីទាំងនេះ កាលពីឆ្នាំមុន និងរហូតដល់បច្ចុប្បន្ននេះ។ ឧទាហរណ៍រួមមាន:

**តាខ្មៅ:** ស្រ្តីមួយរូបដែលធ្វើការឲ្យឡតដ្ឋមួយ ត្រូវបានចាប់ខ្លួន និងឃុំខ្លួនក្នុងខែមីនាពីបទលួចលុយ ១០០ ដុល្លារអាមេរិករបស់ម្ចាស់ឡតដ្ឋ។ ស្ត្រីនោះបានសងប្រាក់ទៅម្ចាស់ដើមវិញ ប៉ុន្តែបច្ចុប្បន្នគាត់នៅតែបន្តស្ថិតនៅក្នុងការឃុំខ្លួនបណ្ដោះអាសន្ន ដើម្បីរង់ចាំសវនាការនៅឡើយ។

**តាខ្មៅ:** ស្ត្រីមួយរូបមានកូន ៧ នាក់ត្រូវបានចាប់ខ្លួនក្នុងខែកុម្ភៈ ឆ្នាំ២០១១ ពីបទលួចសណ្ដែកខៀវមួយកន្ត្រក ដើម្បីយកមកចិញ្ចឹមកូនៗរបស់គាត់។ ស្ត្រីនេះ ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារចំនួន ៦ ខែហើយក្រោយមកត្រូវបានដោះលែងវិញនៅចុងឆ្នាំ ២០១១។

**កំពត:** បុរសម្នាក់ត្រូវបានចាប់ខ្លួនក្នុងខែតុលា ឆ្នាំ២០១១ ហើយផ្តន្ទាទោសពីបទលួចធុងសាំងទទេមួយដោយប្រើអំពើហិង្សា។ បុរសនោះ ត្រូវបានកាត់ទោសអោយជាប់ពន្ធនាគារចំនួន ៣ឆ្នាំ ហើយគាត់កំពុងនៅបម្រើទោសក្នុងពន្ធនាគារនៅឡើយ គិតមកត្រឹមខែមិថុនា ឆ្នាំ២០១២។

**កំពត:** ក្មេងប្រុសចំនួន ៥ នាក់ និងយុវជនដែលមានអាយុពី ១៦ ឆ្នាំ និង១៨ឆ្នាំ បានលួចទូរស័ព្ទដៃមួយគ្រឿង ហើយត្រូវកាត់ទោសឲ្យជាប់ពន្ធនាគារ ៦ខែ។ ពួកគេត្រូវបានដោះលែងនៅដើមឆ្នាំ២០១២ បន្ទាប់ពីបានបម្រើទោសរបស់ពួកគេចប់សព្វគ្រប់។

**ព្រះសីហនុ:** ក្មេងប្រុសអាយុ ១៦ ឆ្នាំម្នាក់ត្រូវបានចាប់ខ្លួនក្នុងខែកុម្ភៈ ឆ្នាំ២០១២ ហើយជាប់ចោទពីបទចោរកម្ម បន្ទាប់ពីបានយករបស់របរដែលម្ចាស់គេទុកនៅក្រៅផ្ទះ។ ក្មេងនេះកំពុងស្ថិតនៅក្នុងការឃុំខ្លួនបណ្ដោះអាសន្ន គិតមកត្រឹមពាក់កណ្ដាលខែមិថុនា ឆ្នាំ ២០១២ នេះ។

ការផ្តន្ទាទោសជនក្រីក្រដាក់ពន្ធនាគារ បន្តជំរុញឲ្យមានភាពចង្អៀតណែនច្រើនបែបយ៉ាង រួមមានៈ

- **ឃុំលើសពេលកំណត់ដោយគ្មានលទ្ធភាពបង់ប្រាក់ពិន័យៈ** ទង្វើពន្យារពេលឃុំខ្លួនសម្រាប់ជនជាប់ឃុំ ដែលពួកគេគ្មានលទ្ធភាពបង់ប្រាក់ពិន័យខាងព្រហ្មទណ្ឌនៅតែបន្តកើតមាន។ ការអនុវត្តបែបនេះ អាចថែមរយៈពេលរហូតដល់ទៅ ២ឆ្នាំបន្ថែមពីលើទោសដែលបានកំណត់ ប៉ុន្តែព្រះរាជអាជ្ញាអាចបដិសេធការអនុវត្តបែបនេះបាន[២៤]។ អង្គការលីកាដូ សង្ឃឹមថា ការប្រើប្រាស់ការបដិសេធនគួរតែត្រូវបានពង្រីកឲ្យបានធំធេង។
- **ការពិបាកក្នុងការដោះលែងជនជាប់ឃុំទាន់ពេលវេលាៈ** ការអនុវត្តក្រៅផ្លូវការដោយបុគ្គលិកពន្ធនាគារ និងតុលាការដែលថាមានភាពមមាញឹកពេក ដែលមិនអាចចាត់ការសំណុំបែបបទដោះលែងជនជាប់ឃុំទាន់ពេលវេលានៅតែបន្តកើតមាន។ ទង្វើបែបនេះ ជាញឹកញាប់ត្រូវបានគេប្រើជាទម្លាប់មួយសម្រាប់មន្ត្រីស្នើសុំឲ្យបង់ប្រាក់ជាសំណូក។ អង្គការលីកាដូ បានចងក្រងជាឯកសារនូវករណីយ៉ាងច្រើនសន្ធឹកសន្ធាប់ក្នុងនោះជនជាប់ឃុំ ត្រូវបានគេឃុំខ្លួនលើសទោសកំណត់ ដោយសារសំណុំបែបបទមានការយឺតយ៉ាវ ឬមិនបានបំពេញសំណុំបែបបទ។ មធ្យោបាយមួយដើម្បីលើកទឹកចិត្តឲ្យមានការដោះលែងជនជាប់ឃុំទាំងអស់ទាន់ពេលវេលា គួរតែត្រូវបង្កើតប្រព័ន្ធមួយដែលតាមរយៈនេះ ត្រូវទូទាត់ជាប្រាក់ដល់ជនជាប់ឃុំនៅពេលណាពួកគេមិនត្រូវបានដោះលែងទាន់ពេលវេលាទេនោះ។
- **កង្វះខាតមេធាវីការពារក្តីៈ** អ្នកស្រាវជ្រាវពីអង្គការលីកាដូ មានការលំបាកជាយូរមកហើយក្នុងការជួយរកមេធាវីមិនយកកម្រៃ ដើម្បីការពារជនជាប់ឃុំបណ្តោះអាសន្នរងចាំសវនាការ ជាពិសេសជនជាប់ឃុំនៅតាមបណ្តាខេត្ត។ បញ្ហានេះ កាន់តែមានភាពធ្ងន់ធ្ងរឡើងកាលពីពីរឆ្នាំមុន ដោយសារអង្គការជំនួយផ្នែកច្បាប់ក្រៅរដ្ឋាភិបាលធំៗ មួយចំនួនបានកាត់បន្ថយបុគ្គលិក[២៥] ដូចជាគម្រោងអ្នកការពារក្តីកម្ពុជា និងអង្គការជំនួយផ្នែកច្បាប់កម្ពុជា។

---

[២៤] ក្រមនីតិវិធីព្រហ្មទណ្ឌត្រង់មាត្រា ៥២៣ - ៥៣៣។

[២៥] បញ្ជីបុគ្គលិកសម្រាប់គម្រោងអ្នកការពារក្តីកម្ពុជាពីខែកញ្ញា ឆ្នាំ២០០៩ ជាឧទាហរណ៍ មានមេធាវីការពារក្តីចំនួន ២២ នាក់។ គេហទំព័ររបស់ខ្លួនប្រាប់ឲ្យដឹងថា បច្ចុប្បន្នមានមេធាវីចំនួន ៩ នាក់ប៉ុណ្ណោះកំពុងបំពេញការងារ។ សូមមើលគេហទំព័រ:http://www. cdpcambodia.org/content.php?id=11.

ជនជាប់ឃុំដែលមានលទ្ធភាពរកមេធាវី ទោះជាជួល ឬមិនយកកម្រៃក៏ដោយជារឿយៗត្អូញត្អែ ថាមេធាវីរបស់ពួកគេពុំមានពេលប្រាស្រ័យទាក់ទងជាមួយពួកគេទេ ដោយសារមានបន្ទុករឿងក្តីច្រើនពេក។ ទណ្ឌិតភាគច្រើនបានរាយការណ៍ប្រាប់ឲ្យដឹងថា ពួកគេបានជួបមេធាវីរបស់គេតែម្តងគត់ គឺនៅថ្ងៃបើកសវនាការ។

ទិន្នន័យពីគម្រោងឃ្លាំមើលតុលាការ ដែលប្រតិបត្តិដោយ NGO ផ្សេងៗគាំទ្រនូវអ្វីដែលអង្គការលីកាដូ មើលឃើញក្នុងពន្ធនាគារនានា។ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានរាយការណ៍ក្នុងខែមីនា ថាជនជាប់ចោទជាង ១/៣ នៅសាលាដំបូងរាជធានីភ្នំពេញពុំមានមេធាវីការពារក្តីឡើយក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋជាង ៤០%[២៦]។ ជំនួយមេធាវី គឺជាការចាំបាច់ត្រូវតែមានសម្រាប់អនីតិជន និងជនត្រូវចោទពីបទឧក្រិដ្ឋ[២៧] និងអាចណែនាំឲ្យមានមេធាវីនៅក្នុងចំណាត់ការនីតិវិធីណាមួយក៏បាន។ ការខ្វះជំនួយផ្នែកច្បាប់នៅពេលសវនាការធ្វើឲ្យជនជាប់ចោទបាត់បង់ផលប្រយោជន៍ ហើយបង្កើនឱកាសប្រថុយប្រថានសម្រាប់ជនជាប់ចោទទទួលរងការកាត់ទោសមិនត្រឹមត្រូវ ឬទទួលរងទោសរយៈពេលវែង។

ក្នុងករណីខ្លះ ចៅក្រមចាត់តាំងមេធាវីមួយរូបផងដែរ សម្រាប់ការពារជនជាប់ចោទមួយក្រុម។ ការអនុវត្តបែបនេះ មិនល្អទេ បើសិនជាជនជាប់ចោទក្នុងករណីដូចគ្នាអាចមានទំនាស់ផលប្រយោជន៍។

## ការសាងសង់ពន្ធនាគារ

អគ្គនាយកដ្ឋានពន្ធនាគារ បានបន្តកិច្ចខិតខំក្នុងការបង្កើនទំហំពន្ធនាគារទូទាំងប្រទេសទាំងតាមរយៈសាងសង់អគារថ្មីៗបន្ថែម និងពង្រីកអគារដែលមានស្រាប់។ ថ្វីបើអគារពន្ធនាគារមួយចំនួនត្រូវការកែលំអបន្ថែមទៀតក៏ដោយ ក៏អង្គការលីកាដូគ្រាន់តែជួយគាំទ្រដល់ការសាងសង់អគារថ្មីៗ ដែលជាដំណោះស្រាយចុងក្រោយ បន្ទាប់ពីបានរកឃើញជម្រើសផ្សេងៗសម្រាប់កាត់បន្ថយចំនួនជនជាប់ឃុំ។ ការសាងសង់អគារពន្ធនាគារថ្មីៗបន្ថែម គឺមានតម្លៃថ្លៃ ហើយតាមប្រវត្តិរឿងមានបំណងបង្កើតប្រសិទ្ធភាព ពង្រីកចំនួនជនជាប់ឃុំនៅតាមពន្ធនាគារទាំងមូល។

---

[២៦] Bridget di Certo and ChhayChannyda "ជនជាប់ចោទនៅរាជធានីខ្វះមេធាវី: ការសិក្សាស្រាវជ្រាវ" កាសែត Phnom Penh Post ចេញផ្សាយថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១២។

[២៧] ក្រមនីតិវិធីព្រហ្មទណ្ឌត្រង់មាត្រា ៣០១។

បញ្ហាគឺនៅត្រង់ថា រដ្ឋាភិបាលបន្តប្រើប្រាស់ការសាងសង់អគារពន្ធនាគារថ្មីៗបន្ថែម ដែលជាដំណោះស្រាយលើកដំបូងរបស់ខ្លួន។ ហើយសម្រាប់គោលបំណងជាក់ស្តែង ដំណោះស្រាយនេះនៅតែជាដំណោះស្រាយតែមួយគត់ ដែលកំពុងត្រូវបានគេប្រើប្រាស់។ នៅក្នុងខែកុម្ភៈ ឆ្នាំ២០១២ អគ្គនាយកដ្ឋានពន្ធនាគារបានរាយការណ៍ថា គម្រោងសាងសង់អគារពន្ធនាគារខាងក្រោម ដែលទាក់ទងនឹងការបង្កើនទំហំ បានកើតឡើងនៅអំឡុងឆ្នាំ ២០១១[២៨] ។

- ការសាងសង់បន្ទប់ឃុំខ្លួនថ្មីបន្ថែមនៅពន្ធនាគារខេត្តព្រៃវែង (ផ្តល់មូលនិធិពីរដ្ឋាភិបាល និងCCJAP) អង្គការលីកាដូមិនឃ្លាំមើលពន្ធនាគារនេះទេ ហើយអគ្គនាយកដ្ឋានពន្ធនាគារមិនបានប្រកាសឲ្យដឹងថា មានចំនួនកន្លែងបន្ថែមប៉ុន្មានទេ។
- ការសាងសង់បន្ទប់ឃុំខ្លួនថ្មីបន្ថែមនៅពន្ធនាគារខេត្តកំពង់ចាម (ផ្តល់មូលនិធិពី CCJAP) ដែលមានកន្លែងបន្ថែមចំនួនប្រហែល ១០០។
- ការសាងសង់បន្ទប់ឃុំខ្លួនថ្មីបន្ថែម សម្រាប់ជនជាប់ឃុំជាស្ត្រីនៅពន្ធនាគារខេត្តកំពង់ធំ (ផ្តល់មូលនិធិពី CCJAP) ដែលមានកន្លែងបន្ថែមចំនួនប្រហែល ១០០។
- បន្តការសាងសង់អគារឃុំខ្លួនថ្មីចំនួន ៣ បន្ថែមនៅមណ្ឌលអប់រំកែប្រែទី១ ដែលនឹងត្រូវបញ្ចប់ការសាងសង់ទាំងស្រង់ក្នុងឆ្នាំ២០១២ ហើយនឹងបន្ថែមចំនួនកន្លែង ដែលមិនទាន់ដឹងចំនួន។
- ការសាងសង់បន្ទប់ឃុំខ្លួនថ្មីបន្ថែមសម្រាប់ជនជាប់ឃុំជាស្ត្រី នៅពន្ធនាគារខេត្តក្រចេះ និងខេត្តស្ទឹងត្រែង (ផ្តល់មូលនិធិពីរដ្ឋាភិបាល) អង្គការលីកាដូ មិនឃ្លាំមើលពន្ធនាគារទាំងនេះទេ ហើយអគ្គនាយកដ្ឋានពន្ធនាគារមិនបានប្រកាសឲ្យដឹងថាមានចំនួនកន្លែងបន្ថែមប៉ុន្មានទេ។

អគារពន្ធនាគារថ្មីមួយបណ្តោះអាសន្ន ត្រូវបានបើកឲ្យដំណើរការផងដែរនៅខេត្តឧត្តរមានជ័យ តាមដឹងមកថាអគារនេះ នៅជាប់នឹងអង្គភាពឃាត់ខ្លួនរបស់មន្ត្រីនគរបាលយុត្តិធម៌។ អគ្គនាយកដ្ឋានពន្ធនាគារបានរាយការណ៍ថា អគារនេះ បានផ្ទុកជនជាប់ឃុំប្រមាណ ៩៤ នាក់គិតមកត្រឹមខែវិច្ឆិកា ឆ្នាំ២០១១។ អគ្គនាយកដ្ឋានពន្ធនាគារមិនបានផ្តល់

[២៨] សូមមើលអគ្គនាយកដ្ឋានពន្ធនាគារ "របាយការណ៍ស្តីពីសមិទ្ធិផលការងារនៅឆ្នាំ២០១១ និងគោលដៅសម្រាប់ឆ្នាំ២០១២" បោះពុម្ពផ្សាយនៅខែកុម្ភៈ ឆ្នាំ២០១២ (បកប្រែក្រៅផ្លូវការជាភាសាអង់គ្លេស)។

ការប៉ាន់ប្រមាណអំពីទំហំផ្ទុករបស់អគារនោះទេ។ អង្គការលីកាដូមិនមានការិយាល័យនៅក្នុងខេត្តឧត្តរមានជ័យទេ ហើយក៏មិនធ្លាប់ចុះទៅមើលពន្ធនាគារថ្មីនេះដែរ។

ផែនការសម្រាប់អនាគតរួមមាន:[២៩]

- ការសាងសង់ពន្ធនាគារថ្មីនៅខេត្តតាកែវ ប៉ៃលិន ឧត្តរមានជ័យ ពោធិ៍សាត់ ខេត្តព្រះសីហនុ[៣០] ខេត្តមណ្ឌលគីរី និងរាជធានីភ្នំពេញ។
- ការបន្តពង្រីកមណ្ឌលអប់រំកែប្រែទី៤។
- កិច្ចព្រមព្រៀងដោះដូរដីធ្លីនៅខេត្តរតនៈគីរី ដើម្បីសាងសង់ពន្ធនាគារថ្មី។
- លទ្ធភាពក្នុងការសាងសង់មណ្ឌលអប់រំកែប្រែថ្មីបន្ថែមនៅខេត្តក្រចេះ (មណ្ឌលអប់រំកែប្រែទី ៥)។



*អ្នកទោសជាបុរសអង្គុយនៅក្នុងរនាំងដែកនៃពន្ធនាគារខេត្តប៉ៃលិន។ ពន្ធនាគារនេះ ជាអតីតរោងភាពយន្ត ហើយបានចាប់ដំណើរការកាលពីឆ្នាំ២០១១ ក្នុងនាមជាពន្ធនាគារបណ្តោះអាសន្ន ប៉ុន្តែការសាងសង់ពន្ធនាគារពិតប្រាកដនៅមិនទាន់ចាប់ផ្តើមនៅឡើយ។*

គម្រោងទាំងនេះ ភាគច្រើនទំនងជាត្រូវប្រើពេលរាប់ឆ្នាំ ដើម្បីបញ្ចប់ការងារសាងសង់។ ពិតហើយនៅតែមិនទាន់បានកំណត់កាលបរិច្ឆេទបញ្ចប់ការងារសាងសង់សម្រាប់ពន្ធនាគារថ្មីនៅខេត្តប៉ៃលិន ដែលជាពន្ធនាគារត្រូវការជាបន្ទាន់ ដោយសារបច្ចុប្បន្នជនជាប់ឃុំរស់នៅក្នុងរោងភាពយន្តមួយចាស់ទ្រុឌទ្រោម។ លក្ខខណ្ឌឃុំខ្លួនមានសភាពធ្ងន់ធ្ងរជាងគេបំផុតក្នុងចំណោមពន្ធនាគារទាំងអស់នៅកម្ពុជា - គ្មានទីធ្លាចំហសម្រាប់ជនជាប់ឃុំចេញមកទទួលខ្យល់អាកាស ឬពន្លឺថ្ងៃឡើយ ហើយជនជាប់ឃុំជាបុរសត្រូវបានឃុំខ្លួនក្នុងទ្រុងមួយ។ អគារនេះមិនសមនឹងយកមកធ្វើជាពន្ធនាគារសម្រាប់ដាក់មនុស្សទេ។ បច្ចុប្បន្ន

[២៩] ដកស្រង់ចេញពីប្រភពឯកសារដូចគ្នា។

[៣០] ការសាងសង់ពន្ធនាគារថ្មីនៅខេត្តព្រះសីហនុមិនមានលើកឡើងក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋានពន្ធនាគារឡើយ ប៉ុន្តែវិទ្យុអាស៊ីសេរីបានរាយការណ៍នៅឆ្នាំ២០១២ ថាជនជាប់ឃុំប្រហែល ២០ នាក់បានជួយកងកម្លាំងរដ្ឋាភិបាលដើម្បីកំទេចផ្ទះសម្បែងអ្នកភូមិរស់នៅក្នុងក្រុម ១៦ សង្កាត់ ១ ក្រុងព្រះសីហនុ។ ដីធ្លីរបស់អ្នកភូមិតាមរាយការណ៍មក ថានឹងត្រូវប្រើប្រាស់សម្រាប់សាងសង់ពន្ធនាគារថ្មី។ សូមមើលវិទ្យុអាស៊ីសេរី "ជនជាប់ឃុំកំទេចផ្ទះសម្បែង" ចេញផ្សាយនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១២ មានក្នុងគេហទំព័រ: http://www. rfa.org/khmer/indepth/prisoners_distroy_house-05232012082645.html។

មិនទាន់ច្បាស់នៅឡើយថា តើរដ្ឋាភិបាលមានបានលៃលកមូលនិធិសម្រាប់គម្រោងនេះ ឬយ៉ាងណាទេ។

## ការគណនាទំហំផ្ទុក

កម្មវត្ថុមួយ ដែលមិនបានលើកក្នុងរបាយការណ៍ប្រចាំឆ្នាំ២០១២ របស់អគ្គនាយកដ្ឋានពន្ធនាគារនោះ គឺការសិក្សាស្រាវជ្រាវដ៏ទូលំទូលាយមួយ ស្តីពីទំហំផ្ទុកចំនួនជនជាប់ឃុំនៅតាមពន្ធនាគារបច្ចុប្បន្ន។ សូម្បីតែរបាយការណ៍នេះ ក៏មិនមានផ្តល់តួលេខអំពីទំហំផ្ទុក (ថ្វីបើតួលេខនេះ ត្រូវបានប្រព័ន្ធផ្សព្វផ្សាយព័ត៌មានធ្វើការផ្សព្វផ្សាយថាមានចំនួន ៩,០០០នាក់ក៏ដោយ)[៣១]។

អគ្គនាយកដ្ឋានពន្ធនាគារមិនដែលបានអនុម័តជាសារធារណៈនូវបទដ្ឋានទំហំផ្ទៃដីសម្រាប់ជនជាប់ឃុំម្នាក់ៗឡើយ ហើយក៏មិនដែលបានធ្វើការសិក្សាស្រាវជ្រាវសមស្របទូទាំងប្រទេស ស្តីអំពីទំហំផ្ទុកចំនួនជនជាប់ឃុំនៅតាមពន្ធនាគារ ដោយផ្អែកលើបទដ្ឋានបែបនេះឡើយ។ អាស្រ័យហេតុនេះ ទើបភាពត្រឹមត្រូវនៃតួលេខផ្ទុកនៅតាមពន្ធនាគារកម្ពុជាមានភាពខុសគ្នាយ៉ាងខ្លាំង។

ថ្វីបើមិនទាន់មានបទដ្ឋានអន្តរជាតិ សម្រាប់គ្រប់គ្រងទំហំផ្ទៃដីឲ្យបានសមស្របដែលត្រូវផ្តល់ឲ្យជនជាប់ឃុំម្នាក់ៗក៏ដោយ ក៏គណៈកម្មាធិការអឺរ៉ុប ដើម្បីទប់ស្កាត់អំពើទារុណកម្មបានលើកអនុសាសន៍ថា យ៉ាងតិចណាស់ជនជាប់ឃុំម្នាក់ៗត្រូវទទួលបានទំហំផ្ទៃដី ៤ ម៉ែត្រការ៉េសម្រាប់បន្ទប់ឃុំខ្លួនដែលមានជនជាប់ឃុំច្រើន[៣២]។ គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិបានបញ្ជាក់ថា "ទោះស្ថិតក្នុងស្ថានភាពមានវិបត្តិពិសេសក៏ដោយ ក៏ផ្ទៃក្រឡាឥដ្ឋក្នុងបន្ទប់ឃុំខ្លួន និងអគារច្រើនជាន់មិនត្រូវឲ្យមានទំហំតូចជាង ២ ម៉ែត្រការ៉េឡើយសម្រាប់ជនជាប់ឃុំម្នាក់ៗ"[៣៣]។

---

[៣១] KuchNaren and Kate Bartlett, "ពន្ធនាគារកម្ពុជាមានសមត្ថភាពផ្ទុក ១៧១% នៅឆ្នាំ ២០១១" កាសែត The Cambodia Daily ចេញផ្សាយនៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០១២។

[៣២] គេហទំព័រ: http://www.coe.int/t/commissioner/Viewpoints/070305_en.asp។

[៣៣] គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ "ទឹក អនាម័យ និងការរស់នៅក្នុងពន្ធនាគារ" ខែសីហា ឆ្នាំ២០០៥ ត្រង់ទំព័រ២១ (មានក្នុងគេហទំព័រ: http://www.icrc.org/eng/resources/documents/publication/p0823.htm)។

តាមការស្រាវជ្រាវចង្អុលបង្ហាញ ថាអគ្គនាយកដ្ឋានពន្ធនាគារដំបូងប្រើប្រាស់បទដ្ឋានទំហំផ្ទៃដី ២ ម៉ែត្រការ៉េ ដែលមិនសមរម្យទាល់តែសោះ។ បទដ្ឋាននេះ គឺជាការកង្វល់ ដោយសារតែជនជាប់ឃុំនៅតាមពន្ធនាគារភាគច្រើន ត្រូវបានផ្តល់ពេលវេលាមានកំណត់ សម្រាប់ចេញក្រៅបន្ទប់ឃុំខ្លួនរបស់ពួកគេ។

ហេតុដូច្នេះ ទំហំផ្ទុកចំនួនជនជាប់ឃុំពិតប្រាកដនៃប្រព័ន្ធគ្រប់គ្រងពន្ធនាគារកម្ពុជា នៅតែមិនទាន់បានដឹងនៅឡើយ - ហើយតួលេខបច្ចុប្បន្ន ដែលលើកឡើងដោយរដ្ឋាភិបាលដែលថា មានដល់ទៅ ៩,០០០ នាក់ទំនងជាតួលេខមួយខ្ពស់។

អង្គការលីកាដូ សូមរំលឹកអនុសាសន៍របស់ខ្លួនឡើងវិញថា អគ្គនាយកដ្ឋានពន្ធនាគារ គួរតែធ្វើការសិក្សាស្រាវជ្រាវមួយទូទាំងប្រទេសទៅលើពន្ធនាគារទាំងឡាយ - ដោយមានការជួយពីសមភាគីអន្តរជាតិ - ដើម្បីធ្វើការគណនាទំហំផ្ទុកពិតប្រាកដនៅក្នុងប្រព័ន្ធគ្រប់គ្រងពន្ធនាគារ។ ដោយសារលក្ខខណ្ឌឃុំខ្លួននៅពន្ធនាគារកម្ពុជាមានច្រើនលើសលុបផងនោះ អង្គការលីកាដូ សូមលើកអនុសាសន៍ថា ការសិក្សាស្រាវជ្រាវត្រូវប្រើបទដ្ឋានមួយដែលយ៉ាងតិចណាស់មានទំហំផ្ទៃក្រឡាឥដ្ឋ ៣.៥ ម៉ែត្រការ៉េ សម្រាប់ជនជាប់ឃុំម្នាក់ៗ។

## ៣. ការពិនិត្យឡើងវិញនូវអនុសាសន៍នានា

របាយការណ៍ចំនួនពីរចុងក្រោយរបស់អង្គការលីកាដូ ស្តីពីភាពចង្អៀតណែននៅពន្ធនាគារបានផ្តល់នូវអនុសាសន៍យ៉ាងច្រើន ដើម្បីកាត់បន្ថយភាពចង្អៀតណែននៅតាមពន្ធនាគារ។ ខាងក្រោមនេះ អង្គការលីកាដូ សូមបន្តលើកអនុសាសន៍មួយចំនួនក្នុងចំណោមអនុសាសន៍សំខាន់ៗទាំងឡាយ ហើយនឹងពិនិត្យឡើងវិញដោយសង្ខេបនូវវិធានការអ្វីខ្លះ - បើមាន - ដែលរដ្ឋាភិបាលបានចាត់ឲ្យមានឡើងចំពោះអនុសាសន៍ទាំងនេះ។

►►**សូមរដ្ឋាភិបាលលោកមានវិធានការវាយតម្លៃ អំពីគោលនយោបាយយុត្តិធម៌ព្រហ្មទណ្ឌដោយចេញពីទស្សនៈវិស័យជាប្រព័ន្ធច្រើនថែមទៀត ដើម្បីកុំអោយក្រសួងមហាផ្ទៃ និងអគ្គនាយកដ្ឋានពន្ធនាគារដោះស្រាយបញ្ហានេះតែម្នាក់ឯង (ដូចជាបញ្ហាចំនួនច្រើនលើសលុបនៃអ្នកទោសនៅតាមពន្ធនាគារជាដើម)។ នៅក្នុងការផ្តួចផ្តើមគំនិតនេះ សូមមេត្តារាជរដ្ឋាភិបាលលោករៀបចំចងក្រងឡើងនូវព័ត៌មានត្រឹមត្រូវ និងអាចជឿទុកចិត្តបានអំពីចំនួនអ្នកទោសទាំងអស់ដែលឃុំឃាំងនៅតាមពន្ធនាគារ ដែលរួមមានទាំងសេចក្តីពិស្តារអំពីថិរវេលានៃទណ្ឌកម្មជាប់ពន្ធនាគារ បទល្មើសដែលបានប្រព្រឹត្ត និងអាយុរបស់ជនប្រព្រឹត្តល្មើសទាំងអស់នេះ ដើម្បីជួយដល់ការធ្វើសេចក្តីសម្រេចចិត្តនានាចំពោះគោលនយោបាយយុត្តិធម៌ព្រហ្មទណ្ឌ។**

ដូចដែលបានកត់សម្គាល់ខាងលើ រដ្ឋាភិបាលបានមានប្រសាសន៍ជាសាធារណៈទាក់ទងនឹងការអនុវត្តវិធានការផ្សេងៗជំនួសឲ្យការឃុំខ្លួន ប៉ុន្តែមិនទាន់បានធ្វើឲ្យមានភាពជឿនលឿនជាដុំកំភួន និងអាចវាយតម្លៃបានឡើយ។ មន្ត្រីអគ្គនាយកដ្ឋានពន្ធនាគារបន្តទទួលស្គាល់បញ្ហាចង្អៀតណែន ហើយមន្ត្រីមួយចំនួនមានទស្សនៈបើកទូលាយក្នុងការទទួលយកការអនុវត្តទោសដោយមិនឃុំខ្លួន។

សម្រាប់ជាឧទាហរណ៍ប្រធានពន្ធនាគារមួយរូប បានមានប្រសាសន៍ប្រាប់អង្គការលីកាដូ ក្នុងឆ្នាំ២០១២ ថាបុគ្គលិករបស់លោកប្រធានថ្មីៗនេះបានបង្កើតវគ្គមួយ ស្តីពីការធ្វើចំណាត់ថ្នាក់សន្តិសុខជនជាប់ឃុំសម្រាប់ជនជាប់ឃុំចំនួនប្រហែល ៨០ នាក់។ ជនជាប់ឃុំចំនួនជាង ៦០ នាក់ត្រូវ បានចាត់ជាចំណាត់ថ្នាក់ "សន្តិសុខកម្រិតទាប" មានន័យថា

(សូចនាករ) បង្ហាញអោយឃើញថា ពួកគាត់អាចក្លាយជាបេក្ខជនសមរម្យសម្រាប់គោលការណ៍ទោសមិនឃុំខ្លួន។

ភាពជឿនលឿនខ្លះ ដែលមានកំណត់ត្រូវបានគេចាត់ឲ្យមានឡើងទាក់ទងនឹងការចងក្រង និងបោះពុម្ពផ្សាយនូវទិន្នន័យស្តីពីប្រព័ន្ធគ្រប់គ្រងពន្ធនាគារ។ ជាការកត់សម្គាល់បំផុតនោះ គឺគួរឲ្យកោតសរសើរដល់អគ្គនាយកដ្ឋានពន្ធនាគារ ចំពោះការបោះពុម្ពផ្សាយនូវទិន្នន័យទូទាំងប្រទេសស្តីពីបទល្មើសដែលត្រូវចោទទៅលើជនជាប់ឃុំក្នុងរបាយការណ៍ខែកុម្ភៈ ឆ្នាំ២០១២។ ទិន្នន័យនេះ ជួយបំភ្លឺយ៉ាងច្បាស់ថា ការចាប់ខ្លួនទាក់ទងនឹងសារធាតុញៀនថ្មីៗនេះ កំពុងបង្កឲ្យមានការកើនឡើងនូវចំនួនជនជាប់ឃុំតាមពន្ធនាគារ។ គួរកោតសរសើរអគ្គនាយកដ្ឋានពន្ធនាគារផងដែរ ចំពោះការបន្តឆន្ទៈក្នុងការចែករំលែកទិន្នន័យដល់អង្គការលីកាដូ និងអង្គការសង្គមស៊ីវិលផ្សេងៗទៀត ដើម្បីអាចធ្វើការវិភាគបានទៅលើទិដ្ឋភាពប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។

ទោះបីយ៉ាងណាក៏ដោយ ការធ្វើរបាយការណ៍តាមទិន្នន័យនៅតែមានភាពមិនទៀងទាត់ និងប្រែប្រួលពីពន្ធនាគារមួយទៅពន្ធនាគារមួយ - ហើយសូម្បីតែនៅក្នុងចំណោមប្រភពពីអគ្គនាយកដ្ឋានពន្ធនាគារក៏ដោយ។ ឧទាហរណ៍អង្គការលីកាដូ បានស្នើសុំថា អគ្គនាយកដ្ឋានពន្ធនាគារ គួរតែផ្តល់តួលេខចំនួនជនជាប់ឃុំនៅតាមពន្ធនាគារទូទាំងប្រទេសសម្រាប់ខែឧសភា ឆ្នាំ២០១២ ដើម្បីដាក់បញ្ចូលទៅក្នុងរបាយការណ៍នេះ។ មន្ត្រីជាន់ខ្ពស់មួយរូបពីអគ្គនាយកដ្ឋានពន្ធនាគារបានមានប្រសាសន៍ថា មិនអាចផ្តល់តួលេខនេះបានឡើយ។

នៅទីបំផុតការសិក្សាស្រាវជ្រាវទូទាំងប្រទេសមួយ ស្តីពីទំហំផ្ទុកចំនួនជនជាប់ឃុំនៅតាមពន្ធនាគារ ដោយប្រើប្រាស់បទដ្ឋានទំហំផ្ទៃក្រឡាឥដ្ឋសមស្របមិនទាន់ត្រូវបានធ្វើនៅឡើយទេ។

*អង្គការលីកាដូ សូមរំលឹកឡើងវិញនូវអនុសាសន៍ពីឆ្នាំ២០១០ និងឆ្នាំ២០១១*

**►►សូមក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ និងដៃគូរពាក់ព័ន្ធ លោកគួរតែចាត់នូវវិធានការនានា ដើម្បីបង្កើតឡើងនូវហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានាដើម្បីអនុវត្តក្នុងកម្រិតធំទូលាយមួយនៃការដាក់ទណ្ឌកម្មដោយមិនប្រើតែវិធីឃុំឃាំងក្នុងពន្ធនាគារ។ យន្តការ**

**ទាំងអស់នេះ គួររួមបញ្ចូលទាំងការហ្វឹកហ្វឺន អំពីការប្រើប្រាស់ដ៏ត្រឹមត្រូវនៃការដាក់ទណ្ឌកម្មដោយមិនប្រើការឃុំឃាំងក្នុងពន្ធនាគារដល់ចៅក្រម ព្រះរាជអាជ្ញា បុគ្គលិក និងមេធាវីការពារក្ដី។ យន្តការនេះ ក៏គួរតែមានការបង្កើតនាយកដ្ឋានសាកល្បង ឬការិយាល័យរដ្ឋាភិបាលស្រដៀងគ្នានេះ ដើម្បីផ្ដោតជាសំខាន់លើការគ្រប់គ្រង និងស្ដារនីតិសម្បទា ជនល្មើសដែលទទួលបានការដាក់ទណ្ឌកម្មមិនជាប់ឃុំឃាំងក្នុងពន្ធនាគារ។**

អង្គការលីកាដូ មិនបានឃើញការរីកចម្រើនគួរអោយកត់សម្គាល់លើអនុសាសន៍នេះទេ។ ការប្រើប្រាស់ជម្រើសផ្សេងក្រៅពីការដាក់ពន្ធនាគារនៅតែមានភាពកម្រ។

*អាស្រ័យហេតុនេះ ជាថ្មីម្ដងទៀត អង្គការលីកាដូ សូមផ្ដល់អនុសាសន៍ដែលបានផ្ដល់កាលពីឆ្នាំ២០១០ និងឆ្នាំ២០១១*

►►**សូមក្រសួងយុត្តិធម៌ លោកមេត្តាចាត់វិធានការជាបន្ទាន់ ដើម្បីអនុវត្តសវនាការផ្ដន្ទាទោសមិនឃុំឃាំងក្នុងពន្ធនាគារចំពោះប្រភេទជនល្មើសមួយចំនួន។ សវនាការនេះគួរចាប់ផ្ដើមឡើង ដោយក្រុមការងារពិសេសពិនិត្យមើលឡើងវិញលើករណីដែលអ្នកទោសទាំងអស់ដែលបានវិនិច្ឆ័យទោសអោយជាប់ពន្ធនាគាររយៈពេល ៣ឆ្នាំ ឬតិចជាងនេះ ដែលនេះ អាចជាចំណុចចាប់ផ្ដើមនៃសេវាសហគមន៍។**

អង្គការលីកាដូ មិនបានឃើញការរីកចម្រើនគួរអោយកត់សម្គាល់លើអនុសាសន៍នេះទេ។ *ដូច្នេះ ជាថ្មីម្ដងទៀត អង្គការលីកាដូសូមផ្ដល់អនុសាសន៍ដែលបានផ្ដល់កាលពីឆ្នាំ២០១០ និងឆ្នាំ២០១១។*

►►**សូមក្រសួងយុត្តិធម៌ និងតុលាការ លោកមេត្តាចាប់ផ្ដើមជាបន្ទាន់នូវការបង្កើនការប្រើប្រាស់វិធានការមិនដាក់ពន្ធនាគារក្នុងរយៈពេលមុនសវនាការ ដល់អ្នកជាប់ឃុំឃាំងបណ្ដោះអាសន្នរងចាំសវនាការចំនួនប្រហែលជា ៣,៨០០នាក់។ បច្ចុប្បន្នចំនួននេះបានដាក់បន្ទុកដល់ប្រព័ន្ធពន្ធនាគារប្រទេសកម្ពុជា។ [សេរីភាពនៅក្រៅឃុំមុនពេលសវនាការ] គួរតែជាច្បាប់ ដែលគួរតែអនុវត្តមិនមែនជាអញ្ញត្រកម្ម ឬការលើកលែងទេ ចំពោះបទល្មើសតូចតាច និងបទល្មើសមិនហិង្សា [ស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា២០៣]។**

ចំនួនជនជាប់ឃុំបណ្ដោះអាសន្នរងចាំសវនាការបានថយចុះ ថ្វីត្បិតតែមិនមានការបំភ្លឺឲ្យបានច្បាស់ថា តើការថយចុះនេះដោយសារកំណើននៃការប្រើប្រាស់ការដាក់ឲ្យនៅ

ក្រៅឃុំដោយបង់ប្រាក់ធានា និងការដោះលែងបណ្តោះអាសន្ន ឬយ៉ាងណា។ នៅក្នុងខែមេសា ឆ្នាំ២០១១ អគ្គនាយកដ្ឋានពន្ធនាគារបានរាយការណ៍ថា មានជនជាប់ឃុំបណ្តោះអាសន្នចំនួន ៥.៣៩៤ នាក់នៅទូទាំងប្រទេស។ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១១ (មានទិន្នន័យថ្មីបំផុតទូទាំងប្រទេស) ចំនួនជនជាប់ឃុំបណ្តោះអាសន្នមាន ៤.១៩៩ នាក់។

បញ្ហាស្មុកស្មាញនោះ គឺភាពទុកចិត្តបានទៅលើទិន្នន័យ។ ឧ: មិនមានភាពច្បាស់លាស់ថាតើ ជនជាប់ឃុំបណ្តោះអាសន្នរងចាំសវនាការ ត្រូវបានគេរាប់ចំនួននៅគ្រប់ពន្ធនាគារ ឬយ៉ាងណា។ ឧ: តាមការសិក្សាស្រាវជ្រាវពីអង្គការលីកាដូបង្ហាញថា ពន្ធនាគារខ្លះអាចចាត់ជនជាប់ឃុំជាចំណាត់ថ្នាក់ "មុនការជំនុំជំរះក្តី" រហូតទាល់តែពន្ធនាគារទទួលបានសាលក្រម/សាលដីកាស្ថាពរពីតុលាការ។ ជនជាប់ឃុំ ដែលនៅជាប់បណ្តឹងឧទ្ធរណ៍ ចាត់ទុកថាពួកគេមិនមាន "សាលក្រម/សាលដីកាស្ថាពរ" ឡើយ។

*អង្គការលីកាដូសូមស្វាគមន៍ ចំពោះការបង្ហាញអោយឃើញនូវការថយចុះចំនួនជនជាប់ឃុំបណ្តោះអាសន្នរងចាំសវនាការ ក៏ប៉ុន្តែអង្គការលីកាដូសូមរំលឹកអនុសាសន៍ដែលបានផ្តល់កាលពីឆ្នាំ២០១០ និងឆ្នាំ២០១១ ថា រដ្ឋាភិបាលលោកគួរតែបង្កើនការប្រើប្រាស់នូវវិធានការទាំងឡាយដោយមិនធ្វើការឃុំខ្លួនមុនការជំរះក្តី។*

►►**ការឃុំឃាំងក្នុងពន្ធនាគារគួរតែត្រូវបានមើលឃើញថា ជាទណ្ឌកម្មដែលជាជម្រើសចុងក្រោយ ហើយមិនមែនជាជម្រើស ដែលគ្មានជម្រើសអ្វីផ្សេង សម្រាប់លើគ្រប់បទល្មើសទាំងអស់នោះទេ។**

អង្គការលីកាដូ មិនបានឃើញការរីកចម្រើនគួរអោយកត់សម្គាល់លើអនុសាសន៍នេះទេ។

*ដូច្នេះជាថ្មីម្តងទៀត អង្គការលីកាដូ សូមផ្តល់អនុសាសន៍ដែលបានផ្តល់កាលពីឆ្នាំ២០១០ និងឆ្នាំ២០១១ និងសូមមេត្តាជម្រុញអោយមានការវិវឌ្ឍន៍រីកចម្រើនលើផ្នែកបីដាក់លាក់ដូចខាងក្រោមគឺ:*

*(១) កាត់បន្ថយការដាក់ទណ្ឌកម្មធ្ងន់ធ្ងរអោយជាប់ពន្ធនាគារ ចំពោះបទល្មើសតូចតាច ដែលមិនពាក់ព័ន្ធនឹងអំពើហិង្សាលើអ្នកដទៃ និង*

*(២) លុបបំបាត់ការអនុវត្តនៃការបន្ថែមរយៈពេលជាប់ឃុំឃាំងក្នុងពន្ធនាគារ ចំពោះទណ្ឌកម្មទាក់ទងនឹងការមិនបង់ប្រាក់ពិន័យ ឬក៏ដាក់ទណ្ឌកម្មរបៀបនេះទន្ទឹមគ្នានឹងរយៈពេលនៃទោសជាប់ពន្ធនាគារពីដំបូង និង*

*(៣) ធ្វើការពិនិត្យឡើងវិញនូវគោលនយោបាយប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌជុំវិញបទល្មើសគ្រឿងញៀន ដោយមានគោលដៅកាត់បន្ថយការប្រើប្រាស់ការបន្ថែមទោសពន្ធនាគារ និងបង្កើនជំរើសផ្សេងៗតាមបែបព្យាបាលប្រកបដោយប្រសិទ្ធភាព និងមិនឃុំខ្លួន។*

□□□

របាយការណ៍នេះបោះពុម្ពក្រោម
ជំនួយឧបត្ថម្ភផ្នែកហិរញ្ញវត្ថុពីសហគមន៍អឺរ៉ុប